# របាយការណ៍សិក្សាស្រាវជ្រាវពី



## “ផលប៉ះពាល់នៃវិបត្តិពីការរីករាលដាលជំងឺកូវីដ ១៩ មកលើសិស្ស និស្សិតនៅក្នុងប្រទេសកម្ពុជា”

ខែសីហា ឆ្នាំ២០២០

# មាតិកា


សេចក្តីថ្លែងអំណរគុណ
របកគំហើញសង្ខេប ៣
**សេចក្តីផ្តើម** ៤
អំពីគោលបំណងនៃការសិក្សាស្រាវជ្រាវ ៥
វិធីសាស្ត្រ និងកម្រិតភាព ៦
ព័ត៌មានរបស់សិស្ស-និស្សិត ៨
**របកគំហើញនៃការសិក្សាស្រាវជ្រាវ**
ការទទួលបានព័ត៌មានពីវិធាន និងការឆ្លើយតបនានាទៅលើការវិវដ្តនៃជំងឺ កូវីដ ១៩ ៩
ផលប៉ះពាល់នៃការផ្អាកដំណើរការគ្រឹះស្ថានអប់រំ ១១
បទពិសោធនៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិក ១៣
ការចំណាយរបស់សិស្ស-និស្សិតមុន និងអំឡុងពេលនៃជំងឺកូវីដ ១៩ ១៥
ផលប៉ះពាល់លើចំណូលរបស់ឪពុកម្តាយ/អាណាព្យាបាល ១៧
ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះអាហារ ១៩
ផលប៉ះពាល់ និងបញ្ហាប្រឈមនឹងកង្វះទឹក ២១
បញ្ហាសុខភាព ការទទួលបានការថែទាំ និងព្យាបាល ២២
ការដោះស្រាយបញ្ហា និងត្រៀមខ្លួនរបស់សិស្សនិស្សិត ២៣
**សេចក្តីសន្និដ្ឋាន**
តម្រូវការចម្បងៗ និងសំណើររបស់សិស្សនិស្សិត ២៣
**ឯកសារយោង**

## សេចក្តីថ្លែងអំណរគុណ

ក្រុមការងារនៃអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ គម្រោងផ្តោតទៅលើលោកខាងត្បូង និងសមាគមក្រុមតន្រ្តីយុវវ័យនាំសារ សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅចំពោះសិស្ស-និស្សិត ឪពុកម្តាយ/អាណាព្យាបាលដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ប្អូនៗ ព្រមទាំងលោក/លោកស្រី ដែលជាអាណាព្យាបាលក្នុងកិច្ចសម្ភាសន៍ជាមួយក្រុមការងារយើងខ្ញុំ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះនិស្សិតស្ម័គ្រចិត្តជាច្រើននាក់ ដែលកំពុងសិក្សានៅមហាវិទ្យាល័យមួយចំនួនក្នុងរាជធានីភ្នំពេញ និងនៅខេត្តបាត់ដំបងចំពោះការចូលរួមយ៉ាងសកម្មរបស់ប្អូនៗ ទាំងកម្លាំងកាយចិត្ត ជាពិសេសនៅក្នុងដំណើរ ការប្រមូលព័ត៌មាន និងបញ្ចូល ទិន្នន័យនៅក្នុងការសិក្សាស្រាវជ្រាវ។

យើង ខ្ញុំក៏សូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដល់ក្រុមការងារបច្ចេកទេសនៃសម្ព័ន្ធបងប្អូនស្រី ព្រមទាំងក្រុមការងារ និងសមាជិកបងប្អូនស្រីទាំងអស់ដែលបានចូលរួមចំណែកយ៉ាងសកម្ម ទាំងការគាំទ្រផ្នែកស្មារតីបច្ចេកទេស និងផ្តល់យោបល់មកលើដំណើរការចងក្រង និងផលិតឯកសារស្រាវជ្រាវមួយនេះ។

## របកគំហើញសំខាន់

"ការងារម៉ែពុកនៅប្រទេសកូរ៉េ (ខាងត្បូង) ផ្អាកមួយរយៈហើយ សូម្បីតែលុយបង់ផ្ទះជួលនៅទីនោះក៏ពួកគាត់សឹងតែគ្មានផង យាយប្រាប់ថា ម៉ែពុកចង់ឱ្យខ្ញុំប្រឹងរៀនធ្វើម៉េចប្រឡងបាក់ឌុប (ថ្នាក់ទី១២) ឱ្យចប់។ ប៉ុន្តែខ្ញុំមិនទាន់ដឹងទេថាអាចរៀនដល់ពេលណា ដោយសារនៅទីនេះគ្រួសារខ្ញុំក៏អត់មានចំណូលដែរយាយគាត់ចាស់ហើយរកចំណូលមិនបាន។ ខ្ញុំគិតថាចង់ឡាយលក់ឡេ ឬទៅស៊ីឈ្នួលគេទាន់ពេលសាលារៀនកំពុងបិទ" សម្តីសិស្សស្រីថ្នាក់ទី១២ ម្នាក់នៅក្នុងខេត្តកំពង់ចាម។

- សិស្ស-និស្សិតជិត៤២ភាគរយ បង្ហាញថាពួកគេមានអារម្មណ៍ស្មុគស្មាញ ១៥ភាគរយភ័យខ្លាច បន្ទាប់ពីបានទទួលដំណឹងពីការពន្យារពេលនៃការចូលរៀន។ សិស្ស-និស្សិតមួយចំនួនមានការខ្វល់ខ្វាយពីការអាក់ខានការសិក្សារបស់ពួកគេ ដែលបញ្ហានេះអាចធ្វើឱ្យរាំងស្ទះដល់ការបញ្ចប់ការសិក្សារបស់ពួកគេ។
- សិស្ស-និស្សិតមួយចំនួនថា ពួកគេបានបន្តសិក្សាដោយខ្លួនឯង ក៏ប៉ុន្តែការរៀនបែបនេះ គឺមិនបានគ្រប់ជ្រុងជ្រោយដូចជាការសិក្សានៅក្នុងថ្នាក់រៀនជាមួយគ្រូនោះទេ។
- សិស្ស-និស្សិតមួយចំនួនបារម្ភថា ពួកគេមិនអាចបញ្ចប់ការសិក្សាទៅតាមកាលកំណត់ ហើយត្រូវរៀនសារឡើងវិញ។
- សិស្ស-និស្សិត៤៣.៧ភាគរយ ឆ្លើយថា ពួកគេមិនធ្លាប់រៀនតាមប្រព័ន្ធអេឡិចត្រូនិកពីមុននោះទេ។
- សិស្ស-និស្សិតមួយចំនួនបង្ហាញទស្សនៈថាទោះបីជាការរៀនតាមប្រព័ន្ធ អេឡិចត្រូនិកបានតិចតួចជាងការរៀននៅសាលាដោយផ្ទាល់ក៏ដោយក្តី ក៏វាមានភាពចាំបាច់សម្រាប់ពួកគេ ដោយសារការរៀនតាមប្រព័ន្ធនេះឱ្យពួកគេបន្តការរៀន បាន ហើយក៏ជាការរៀនដោយផ្លាស់ប្តូរវិធីសាស្ត្រថ្មី។
- ពួកគេថា ការសិក្សាតាមប្រព័ន្ធនេះ គឺមិនបានផ្តល់ដល់សិស្សនិស្សិតដោយឥតគិតថ្លៃនោះទេ។ ជាក់ស្តែងដើម្បីអាចរៀនតាមប្រព័ន្ធនេះបាន សិស្ស-និស្សិតត្រូវចំណាយប្រាក់កាសផ្ទាល់ខ្លួនទៅលើឧបករណ៍ ឬសម្ភារៈសិក្សាដូចជាទូរស័ព្ទទំនើប ឬ កំព្យូទ័រ ការចំណាយទៅលើប្រព័ន្ធអ៊ិនធើណែត និងទៅលើអគ្គីសនីជាដើម។
- ដោយសារបញ្ហាកង្វះខាតជីវភាពគ្រួសារ សិស្ស-និស្សិតមួយចំនួនថា ការរៀនតាមប្រព័ន្ធនេះ មិនសមស្របជាមួយនឹងស្ថានភាពរបស់ពួកគេឡើយ។ ពួកគេបន្ថែមថា ពួកគេមានបញ្ហាជាច្រើនដែលត្រូវគិតដូចនេះ ការរៀននេះពេលខ្លះ ជាការបន្ថែមបន្ទុកទៅដល់គ្រួសារពួកគេ។ សិស្ស-និស្សិតមួយចំនួន បង្ហាញនូវអារម្មណ៍បាក់ទឹកចិត្ត ជាពិសេសនៅពេលដែលពួកគេគ្មានលទ្ធភាពចូលរួមរៀនជាមួយមិត្តភ័ក្រ្តដទៃ។
- សិស្ស-និស្សិតមួយចំនួន បានលើកឡើងនូវបញ្ហានៃការបន្តបង់ថ្លៃសិក្សារបស់ពួកគេ ជាមួយគ្រឹះស្ថានអប់រំសាធារណៈ (កម្មវិធីបង់ថ្លៃ) បើទោះបីជាការសិក្សាមានការថយចុះជាងមុនក៏ដោយ។ ពួកគេលើកឡើងថាសាលារដ្ឋគួរមានវិធានការលើកលែងថ្លៃសាលាដល់ពួកគេ ជាពិសេសនៅអំឡុងស្ថានភាពវិបត្តិបែបនេះ។

- សិស្ស-និស្សិត៦.២ភាគរយ ឆ្លើយថាពួកគេមិនមានអាហារទទួលទានគ្រប់គ្រាន់ នាពេលបច្ចុប្បន្ន ឬក៏អំឡុងពេលនៃកិច្ចសម្ភាសន៍។
- សិស្ស-និស្សិត១៨.៣ភាគរយ ថាពួកគេមិនមានទឹកទទួលទាន និងប្រើប្រាស់គ្រប់គ្រាន់នោះទេ នាពេលបច្ចុប្បន្ន តួយ៉ាងគ្រួសារសិស្ស-និស្សិតក្នុងស្រុកចំនួនពីរនៅខេត្តសៀមរាប និងស្រុកមួយចំនួនទៀតក្នុងខេត្តបាត់ដំបង។

## ១. សេចក្តីផ្តើម

ដូចជាបណ្តាប្រទេសជាច្រើននៅក្នុងសកលលោក ប្រទេសកម្ពុជាក៏ទទួលរងនូវផលប៉ះពាល់ពីវិបត្តិនានាដែលបណ្តាលពីការរាតត្បាតនៃជំងឺកូវីដ ១៩ មកលើវិស័យ សុខាភិបាល សង្គម និងសេដ្ឋកិច្ចជាតិ។ ចាប់តាំងពីការរកឃើញករណីមេរោគកូវីដ ១៩លើកទីមួយ[1] រហូតមកដល់សប្តាហ៍ទីពីរនៃខែសីហា ឆ្នាំ២០២០ ប្រទេសកម្ពុជាមានករណីកូវីដ ១៩ ចំនួន២៧៣នាក់។[2] ក្នុងចំណោម២៧៣ករណី ដែលបានរកឃើញ មានអ្នកជំងឺចំនួន២៣៨នាក់បានព្យាបាលសះស្បើយ ហើយ៣៥នាក់ទៀតកំពុងទទួលការព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ និងឯកជន។ គួសបញ្ជាក់ថា ការធ្វើតេស្ត ការថែទាំនិងព្យាបាលជំងឺ កូវីដ ១៩ មិនត្រូវបានគិតថ្លៃ។

វិធានការពារទប់ស្កាត់ចំពោះការរីករាលដាលនៃមេរោគកូវីដ ១៩ ជាច្រើនត្រូវបានដាក់ចេញឱ្យអនុវត្តជាបន្តបន្ទាប់ដោយរាជរដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ ដោយក្នុងនោះមានដូចជាសេចក្តីជូនដំណឹងពីការផ្អាកដំណើរការជាបណ្តោះអាសន្ននៃគ្រឹះស្ថានអប់រំ (ទាំងគ្រឹះស្ថានអប់រំសាធារណៈ និងឯកជន) គ្រឹះស្ថានកំសាន្តឯកជនសណ្ឋាគារ ភោជនីយដ្ឋានធំៗ ក្លឹបហាត់ប្រាណ និងសេវាកម្មឯកជនមួយចំនួន។ បទបញ្ជា និងយន្តការដើម្បីបង្ការផ្តល់ការគាំទ្រឧបត្ថម្ភ និងឆ្លើយតបទៅនឹងវិបត្តិផ្សេងៗដែលកើតឡើងក្នុងអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ ១៩ ដូចជាការរឹតបណ្តឹងការជួបជុំ និងប្រមូលផ្តុំជាសាធារណៈ ការហាមប្រាមការធ្វើដំណើរឆ្លងពីស្រុក ឬ ខេត្តមួយទៅស្រុក ឬ ខេត្តមួយទៀតទូទាំងប្រទេស ការធ្វើចត្តាឡីស័ក ការអនុគ្រោះកាតព្វកិច្ចពន្ធដល់ក្រុមហ៊ុនវិនិយោគ ហើយនាពេលថ្មីៗនេះ ការដាក់ចេញកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺ កូវីដ ១៩ ជាដើម។ល។

វិស័យអប់រំទទួលរងផលប៉ះពាល់ពីមានការផ្ទុះឡើងនៃជំងឺកូវីដ ១៩។ គិតមកទល់បច្ចុប្បន្ន គ្រឹះស្ថានអប់រំនានា ជាពិសេសគ្រឹះស្ថានអប់រំសាធារណៈ (សាលារៀន មហាវិទ្យាល័យ និងសកលវិទ្យាល័យ) បានបិទដំណើរការអស់រយៈពេលជិត៨ខែហើយ គិតចាប់តាំងពីថ្ងៃទី២៩ ខែមករា បន្ទាប់ពីការដាក់ឱ្យអនុវត្តនូវសេចក្តីជូនដំណឹងរបស់ក្រសួងអប់រំយុវជន និងកីឡាស្តីពីការឈប់សម្រាកវិស្សមកាលតូចមុនកាលកំណត់។ វិធានការនេះជាវិធានការដ៏សំខាន់ ដែលក្រសួងអប់រំ យុវជន និងកីឡា ដាក់ចេញដើម្បីបង្ការការរីករាលដាលនៃជំងឺកូវីដ ១៩ ក្នុងចំណោមសិស្ស-និស្សិតនៅទូទាំងប្រទេស។

ការផ្អាកដំណើរការគ្រឹះស្ថានអប់រំសាធារណៈជាពិសេសការបិទដំណើរការជា បណ្តោះអាសន្ននៃសាលារៀន មហាវិទ្យាល័យ និងសកលវិទ្យាល័យសាធារណៈ បាន ផ្តល់ផលប៉ះពាល់ទៅលើពេលវេលា គុណភាព និងប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស-និស្សិតជាច្រើននាក់។ កម្មវិធីសិក្សាមួយចំនួនក៏ត្រូវបានដាក់ចេញឱ្យអនុវត្ត ដែល ក្នុង

---

[1] វិទ្យុវីអូអេ "កម្ពុជាប្រកាសករណីទី១នៃវីរុសកូរ៉ូណាដែលរកឃើញលើជនជាតិចិនម្នាក់នៅខេត្តព្រះសីហនុ" ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ https://khmer.voanews.com/a/first-case-of-coronavirus-confirmed-in-Cambodia/5261841.html

[2] សេចក្រីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលស្តីពីមានករណីជាសះស្បើយ និងមិនមានករណីវិជ្ជមានវីរុសកូវីដ ១៩ ថ្មី នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ https://www.information.gov.kh/detail/483331

នោះរួមមានការរៀនតាមប្រព័ន្ធអ៊ិនធើណែត[3] និងកម្មវិធីមួយចំនួនទៀត[4] ដូចជាការចុះបង្រៀនតាមផ្ទះរបស់លោកគ្រូអ្នកគ្រូដើម្បីជំនួយដល់សិស្សានុសិស្សដែលមានកំពុងសិក្សាក្នុងកម្រិតបឋមសិក្សា និងក្រោមមធ្យមសិក្សាដើម្បីជំនួយដល់ការអប់រំទៅដល់សិស្ស-និស្សិតទូទាំងប្រទេស។

សិស្ស-និស្សិតមានបទពិសោធន៍ និងការយល់ឃើញផ្សេងៗគ្នាទៅលើការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។[5] សិស្ស-និស្សិតមួយចំនួនមានការពេញចិត្ត ហើយថាការរៀន តាមប្រព័ន្ធអេឡិចត្រូនិកផ្តល់ផលប្រយោជន៍ ដល់ការសិក្សារបស់ពួកគេ។ សិស្ស-និស្សិតទាំងនេះ ក៏បានលើនូវបញ្ហាមួយចំនួនដែលពួកគេបានជួបនៃអំឡុងពេលនៃការរៀនតាមប្រព័ន្ធនេះ។ ជាក់ស្តែង ការរៀនតាមប្រព័ន្ធអ៊ិនធើណែតនេះ មិនបានអនុវត្តឡើងដោយមិនគិតថ្លៃនោះទេ។ ដើម្បីអាចរៀនតាមប្រព័ន្ធនេះបាន សិស្ស-និស្សិតត្រូវចំណាយទៅលើ ឧបករណ៍សម្រាប់សិក្សាដូចជាទូរស័ព្ទទំនើប ឬកុំព្យូទ័រ ប្រព័ន្ធអ៊ិនធើណែត និងអគ្គីសនីជាដើម។

វិបត្តិនានាពីការរាតត្បាតនៃជំងឺកូវីដ ១៩ ផ្តល់ផលប៉ះពាល់មកលើវិស័យសំខាន់ៗមួយចំនួន ដែលវិស័យទាំងនោះជាប្រភពចំណូល និងការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋជាច្រើនទាំងប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង និងតំបន់ជនបទ។ ផលប៉ះពាល់នៃការធ្លាក់ចុះ ឬបាត់បង់ប្រភពចំណូលរបស់ឪពុកម្តាយ ឬអាណាព្យាបាលធ្វើឱ្យលទ្ធភាពផ្គត់ផ្គង់ការសិក្សារបស់កូនៗពួកគេ ស្ថិតនៅជាចំណោទសំណួរ។

តាមរយៈការអង្កេតការគាំទ្រ និងឧបត្ថម្ភចំពោះសិស្ស-និស្សិត ជាពិសេសសិស្ស-និស្សិតក្រីក្រ ឬងាយរងគ្រោះ ដែលក្នុងនោះរួមទាំងសិស្ស-និស្សិតមួយចំនួនដែលកំពុងស្នាក់នៅទីរួមខេត្ត ឬទីក្រុងភ្នំពេញដើម្បីបន្តការសិក្សារបស់ពួកគេ នាអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ ១៩ ហាក់មានកម្រិតទាបនៅឡើយ។

របាយការណ៍ស្រាវជ្រាវនេះ បង្ហាញពីបទពិសោធន៍ ផលប៉ះពាល់ និងតម្រូវការរបស់សិស្ស-និស្សិតនាអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ ១៩។ របាយការណ៍នេះ ក៏បញ្ចូលផងដែរនូវសំណើររបស់សិស្ស-និស្សិតជូនរាជរដ្ឋាភិបាល ក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធ។

## ២. អំពីគោលបំណងនៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រ និងកម្រិតភាព

### គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីផលប៉ះពាល់នៃមេរោគកូវីដ ១៩ គឺជាគំនិតផ្តួចផ្តើមរបស់ សម្ព័ន្ធបងប្អូនស្រី រួមជាមួយបណ្តាញពហុវិស័យនៃអង្គការសកម្មភាពប្រជាជនដើម្បីការអភិវឌ្ឍ និងកម្មវិធីផ្តោតលើលោកខាងត្បូង។ ចំពោះការសិក្សាស្រាវជ្រាវស្តីពី "ស្វែងយល់ពីស្ថានភាព និងផលប៉ះពាល់នៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩ មកលើសិស្ស-និស្សិតនៅកម្ពុជា" រៀបចំឡើងដោយ អង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ

[3] សេចក្តីប្រកាសព័ត៌មានចេញដោយក្រសួងអប់រំ យុវជន និងកីឡា ស្តីពី "ការរៀនតាមប្រព័ន្ធអេឡិចត្រូនិ (E-learning) សម្រាប់ជំនួយដល់សិស្សានុសិស្ស" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។ https://drive.google.com/file/d/19KV_MHm2FEgvaena_q_xXKcPqB-ntbn3A/view

[4] ក្រសួងអប់រំយុវជន និងកីឡា ស្តីពី "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" សិស្សានុសិស្សកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ http://www.moeys.gov.kh/index.php/kh/laws-and-legislations/in-struction/i20-23.html#.X03rx-_is2x

[5] របាយការណ៍សង្ខេបស្តីពី "បទពិសោធន៍នៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិក" រៀបចំដោយសកម្មសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍន៍នៅក្នុងខែឧសភា ឆ្នាំ២០២០។

គម្រោងផ្តោតលើលោកខាងត្បូង និងសមាគមក្រុមតន្ត្រីយុវវ័យនាំសារ។

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងក្នុងគោលបំណង ទី១.សិក្សាស្វែងយល់ពីបទពិសោធន៍ ផលប៉ះពាល់ និងតម្រូវការរបស់សិស្ស-និស្សិត នៅអំឡុងពេលវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩ និង ទី២.លើកឡើងនូវសំណើររបស់សិស្ស-និស្សិត ជូនរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជននិងកីឡា និងស្ថាប័នពាក់ព័ន្ធ។

## វិធីសាស្ត្រ

កិច្ចសម្ភាសន៍ធ្វើឡើងដោយក្រុមការងារស្រាវជ្រាវដែលមានការចូលរួមពីនិស្សិតស្ម័គ្រចិត្ត ក្រុមការងារនៃអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ សមាគមន៍ក្រុមតន្ត្រីយុវវ័យនាំសារ បុគ្គលិកបច្ចេកទេសនៃសម្ព័ន្ធបងប្អូនស្រី និងក្រុមការងារនៃគម្រោងផ្តោតទៅលើលោកខាងត្បូង។

វិធីសាស្ត្រប្រមូលព័ត៌មានតាមបែបបរិមាណ និងគុណភាព ត្រូវបានប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវដើម្បីប្រមូលទិន្នន័យ។ កិច្ចសម្ភាសន៍ជាមួយសិស្ស-និស្សិត ព្រមទាំងអាណាព្យាបាល ធ្វើឡើងចាប់ពីថ្ងៃទី២ ដល់ថ្ងៃ១២ ខែឧសភា ឆ្នាំ២០២០។ ក្រុមការងារសិក្សាស្រាវជ្រាវ បន្តតាមដានការវិវឌ្ឍនានានៃការរាតត្បាតនៃជំងឺកូវីដ ១៩ ចាប់តាំងពីពេលកំណត់ការសិក្សាស្រាវជ្រាវ រហូតមកទល់ថ្ងៃដែលរបាយការណ៍នេះ ត្រូវបានបញ្ចប់។

ឯកសារពាក់ព័ន្ធ និងទិន្នន័យមួយចំនួនត្រូវបានពិនិត្យ ដកស្រង់ និងប្រើប្រាស់សម្រាប់ការវិភាគនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ។

កិច្ចសម្ភាសន៍ជាមួយសិស្ស-និស្សិតភាគច្រើន ធ្វើឡើងតាមប្រព័ន្ធទូរស័ព្ទ ហើយមួយចំនួនទៀតតាមរយៈការចុះជួបសម្ភាសជាមួយសិស្ស-និស្សិតដោយផ្ទាល់។ មូលហេតុចំនួនពីរដែលក្រុមការងារសម្រេចធ្វើការជួបសម្ភាសជាមួយសិស្ស-និស្សិត ដោយក្នុងនោះរួមមាន៖ ទី១.បញ្ហារអាក់រអួលនៃការទំនាក់ទំនងរវាងក្រុមការងារស្រាវជ្រាវជាមួយសិស្ស-និស្សិតតាមប្រព័ន្ធទូរស័ព្ទ និង ទី២.សិស្ស-និស្សិតមួយចំនួន ពុំមានទូរស័ព្ទសម្រាប់ទំនាក់ទំនង។ កិច្ចសម្ភាសន៍ធ្វើឡើងចន្លោះពី៣៥នាទី ទៅ មួយម៉ោងកន្លះ។

សូមបញ្ជាក់ថា ការសិក្សាស្ទង់មតិពីបទពិសោធនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់សិស្ស-និស្សិត ត្រូវបានធ្វើឡើងនៅក្នុងខែឧសភា តាមរយៈប្រព័ន្ធអ៊ិនធើណែត បន្ទាប់ពីការប្រកាសដាក់ឱ្យអនុវត្តការរៀនតាមប្រព័ន្ធអេឡិចត្រូនិកដោយក្រសួងអប់រំ យុវជន និងកីឡា[6] ដូចនេះ របាយការណ៍នេះ ក៏បានប្រើប្រាស់របកគំហើញមួយចំនួនពីការសិក្សាស្ទង់មតិនេះ ដោយផ្តោតទៅលើបទពិសោធន៍របស់សិស្ស-និស្សិតក្នុងការរៀនតាមប្រព័ន្ធអ៊ិនធើណែត។

## កម្រិតភាពនៃការសិក្សាស្រាវជ្រាវ

ភូមិសាស្ត្រ និងចំនួនសិស្ស-និស្សិតដែលត្រូវបានជ្រើសរើសសម្រាប់កិច្ចសម្ភាសន៍ ធ្វើឡើងដោយផ្អែកទៅលើធនធាន ពេលវេលា និងលទ្ធភាពរបស់ក្រុមការងារសិក្សាស្រាវជ្រាវនេះ។ ទស្សនៈរបស់ឪពុកម្តាយ ឬអាណាព្យាបាលត្រូវបានបញ្ចូលជាមួយនឹងការឆ្លើយតបរបស់សិស្ស-និស្សិត ដោយសារ ពួកគេចូលរួមមានចំនួនតិចបើប្រៀបធៀបទៅនឹងចំនួនសិស្ស-និស្សិតដែលចូលរួមសម្ភាសន៍ ហើយការចូលរួមរបស់ពួកគេក៏ជា លក្ខណៈបំពេញបន្ថែម

[6] របាយការណ៍សង្ខេបពីលទ្ធផលនៃការស្ទង់មតិ "បទពិសោធន៍នៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (E-learning) របស់សិស្សនិស្សិត" រៀបចំដោយអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០។

ទៅលើព័ត៌មានដែលសិស្ស-និស្សិតបានផ្តល់បទសម្ភាសន៍ជាមួយក្រុមការងារសិក្សាស្រាវជ្រាវ។

បើទោះបីជារាល់ព័ត៌មាន ទិន្នន័យ និងបង្ហាញនៅក្នុងរបាយការណ៍សិក្សាស្រាវជ្រាវនេះ ដោយឆ្លងកាត់ការពិចារណា និងការវិភាគយ៉ាងយកចិត្តទុកដាក់ផ្អែកលើការវិវដ្តនៃស្ថានភាពនៃការរាតត្បាតពីជំងឺកូវីដ ១៩ មកលើសង្គម និងការសិក្សារបស់សិស្ស-និស្សិត និងជីវភាពរស់នៅក្រុមគ្រួសាររបស់ពួកគេក៏ដោយ ក៏ប៉ុន្តែដោយសារកម្រិតភាពនៃធនធាន និងពេលវេលារបស់ក្រុមការងារសិក្សាស្រាវជ្រាវ របាយការណ៍មួយនេះ មិនអាចគ្រប់ដណ្តប់ឱ្យបានគ្រប់ជ្រុងជ្រោយទៅលើផលប៉ះពាល់មួយចំនួនទៀត ដែលបណ្តាលពីការរាតត្បាតនៃជំងឺកូវីដ ១៩ មកលើសិស្ស-និស្សិតនៅក្នុងប្រទេសកម្ពុជា។ ដូចគ្នានេះដែរ ដោយសារកម្រិតភាពរបស់ក្រុមការងារសិក្សាស្រាវជ្រាវកិច្ច សម្ភាសន៍ជាមួយរាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងអាជ្ញាធរមូលដ្ឋាននៅក្នុងការសិក្សាស្រាវជ្រាវមិនត្រូវបានធ្វើឡើងនោះទេ។

សូមបញ្ជាក់ថា លទ្ធផលនៅក្នុងរបាយការណ៍ពីការសិក្សាស្រាវជ្រាវនេះ មិនតំណាងឱ្យបទពិសោធ ឬផលប៉ះពាល់របស់សិស្ស-និស្សិតនៅទូទាំងប្រទេសកម្ពុជានោះទេ។

## ២.៤. អំពីរបាយការណ៍

របាយការណ៍នេះគ្របដណ្តប់ទៅលើបញ្ហាចម្បងៗ មួយចំនួនរួមមាន៖

- សិក្សាស្វែងយល់ពីវិធាន យន្តការឆ្លើយតប និងអន្តរាគមន៍មួយចំនួនរបស់ រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងក្រសួងពាក់ព័ន្ធទៅដល់សិស្ស-និស្សិត។
- ផលប៉ះពាល់នៃការផ្អាកជាបណ្តោះអាសន្ននៃគ្រឹះស្ថានអប់រំមកលើគុណភាព និងប្រសិទ្ធភាពនៃការសិក្សារបស់សិស្ស-និស្សិត។
- ការចំណាយរបស់សិស្ស-និស្សិតមុន និងអំឡុងពេលការរាតត្បាតនៃជំងឺកូវីដ ១៩។
- ផលប៉ះពាល់មកលើប្រភពចំណូល និងការប្រកបរបរចិញ្ចឹមជីវិតរបស់ឪពុក ម្តាយ/អាណាព្យាបាលសិស្ស-និស្សិត។
- ផលប៉ះពាល់ និងបញ្ហាប្រឈមមួយចំនួនរបស់សិស្ស-និស្សិត និងគ្រួសាររបស់ពួកគេ (ការទទួលបានការថែទាំសុខភាព កង្វះអាហារ និងទឹក)។
- តម្រូវការ និងសំណើររបស់សិស្ស-និស្សិតជូនរាជរដ្ឋាភិបាល ក្រសួងអប់រំយុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធនានា។

ដើម្បីរក្សាការសម្ងាត់ និងសុវត្ថិភាពជូនសិស្ស-និស្សិត និងក្រុមគ្រួសាររបស់ពួកគេ ឈ្មោះពិតរបស់ពួកគេមិនត្រូវបានប្រើប្រាស់នៅក្នុងរបាយការណ៍សិក្សាស្រាវជ្រាវនេះឡើយ។ ឈ្មោះដែលក្រុមការងារប្រើប្រាស់នៅក្នុងសម្រង់សម្តីគឺជាការតាងឡើងជំនួសឲ្យឈ្មោះពិតរបស់ពួកគេ។

## ៣. ព័ត៌មានរបស់សិស្ស-និស្សិតដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ

សិស្ស-និស្សិតមានចំនួន៧១នាក់ចូលរួមនៅក្នុងការសិក្សានេះ។ ក្នុងនោះសិស្ស-និស្សិត៥៣.៥ភាគរយ គឺជាស្ត្រី។ ពួកគេមានអាយុចន្លោះពី១៥ឆ្នាំ ទៅ៣២ឆ្នាំ។ ឪពុកម្តាយ ឬអាណាព្យាបាលសិស្ស-និស្សិតមួយចំនួន ជាពិសេសសិស្សដែលមានអាយុក្រោម១៨ឆ្នាំ មានចំនួន២ភាគរយ ចូលរួមក្នុងកិច្ចសម្ភាសន៍។




*ចំនួនសិស្ស-និស្សិត៧១នាក់*




*កម្រិតការសិក្សា*

សិស្ស-និស្សិត៥៦.៦ភាគរយ កំពុងសិក្សា នៅកម្រិតមហាវិទ្យាល័យ ក្នុងនោះ សិស្សនិស្សិតជាង ៥០ភាគរយ កំពុងសិក្សានៅសាលារៀនសាធារណៈ។ សិស្ស- និស្សិតទាំងនេះមានទីលំនៅក្នុងរាជធានីភ្នំពេញ និងនៅក្នុងខេត្តមួយចំនួនទៀតរួមមាន ខេត្តបាត់ដំបង ព្រះសីហនុ កំពង់ចាម សៀមរាប និងខេត្តបន្ទាយមានជ័យ។

[7] រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ លេខ ០០៣ សជន សេចក្តីណែនាំ ស្តីពីការផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ថ្ងៃព្រហស្បតិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០។

[8] ក្រសួងមហាផ្ទៃ លេខ ១០០៧ សជណ ស្តីពីវិធានការគ្រប់គ្រងបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ។ ថ្ងៃសុក្រ ៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០។

[9] រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ លេខ ៩១៦ សជណ ស្តីពីការផ្អាកជាបណ្តោះអាសន្ននូវការធ្វើដំណើរចេញពីប្រទេសរបស់ប្រជាពលរដ្ឋកម្ពុជា ទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម និងការធ្វើដំណើរចូលព្រះរាជាណាចក្រកម្ពុជារបស់ប្រជាពលរដ្ឋវៀតណាម។ ថ្ងៃព្រហស្បតិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០។

សិស្ស-និស្សិតមួយចំនួនទៀត ដែលចំណាកស្រុកមកពីបណ្តាលខេត្តមួយចំនួន ដែលកំពុងស្នាក់នៅក្នុងរាជធានីភ្នំពេញព្រមទាំងទីរួមខេត្តមួយចំនួនដើម្បីបន្តការសិក្សារបស់ពួកគេក៏ត្រូវបានសម្ភាសន៍នៅក្នុងការសិក្សានេះផងដែរ។

## ៤. របកគំហើញនៃការសិក្សាស្រាវជ្រាវ

### ការទទួលបានព័ត៌មាន

#### វិធាន បទបញ្ជា និងយន្តការ

វិធាន និងយន្តការ ត្រូវដាក់ចេញឱ្យបានអនុវត្តជាបន្តបន្ទាប់ដោយរាជរដ្ឋាភិបាល ក្រសួងសុខាភិបាល ក្រសួង អប់រំ យុវជន និងកីឡា និងក្រសួងពាក់ព័ន្ធមួយចំនួនទៀតដើម្បីបង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគកូវីដ ១៩ ព្រមទាំងដើម្បីដោះស្រាយ និងឆ្លើយតបផងដែរទៅនឹងវិបត្តិនានា ដែលកើតឡើងនៅក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺនេះ។ វិធាន និងយន្តការទាំងនោះរួមមានៈការផ្សព្វផ្សាយពីវិធានការបង្ការទប់ស្កាត់ការរាតត្បាតនៃជម្ងឺកូវីដ ១៩ (ក្នុងនោះរួមមានទាំងការកម្រិតការជួបជុំ និងការប្រមូលផ្តុំនៅតាមទីសាធារណៈ)[7] វិធានការគ្រប់គ្រងពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃ[8] ការប្រកាសផ្អាកជាបណ្តោះអាសន្ននូវការធ្វើដំណើរចេញចូលប្រទេសរបស់ប្រជាពលរដ្ឋកម្ពុជាទៅកាន់សាធារណៈរដ្ឋសង្គមនិយមវៀតណាម[9] និងការធ្វើដំណើរចូលព្រះរាជាណាចក្រកម្ពុជារបស់ប្រជាពលរដ្ឋវៀតណាម និងផ្អាកដំណើរការរបស់ប្រជាជនតាមរយៈច្រកចេញចូលអន្តរជាតិនានា អនុក្រឹត្យស្តីពីការលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ និងនិយោជិត កម្មករនាអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិ[10] បទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស[11] សេចក្តីជូនដំណឹងស្តីពីវិធានការបង្ការជំងឺកូវីដ ១៩ នៅ តាម រោ ងចក្រ សហគ្រាសនៅអំឡុងពេលលើកការឈប់សម្រាកបុណ្យចូលឆ្នាំប្រពៃណីជាតិឆ្នាំ២០២០[12] និងសេចក្តីសម្រេចស្តីពីការបញ្ចប់សុពលភាពបទបញ្ជាពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស[13]ជាដើម។ល។

សម្រាប់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់ចេញនូវវិធានមួយចំនួនផងដែរ។ វិធានទាំង នោះមានដូចជា៖ សេចក្តីណែនាំពីការឈប់សម្រាកវិស្សមកាលតូចមុនការកំណត់[14] ការពន្យាពេលនៃការ

---

[10] អនុក្រឹត្យស្តីពី ការលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ នៅថ្ងៃទី១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នាំ២០២០ ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០។ https://www.moeys.gov.kh/index.php/kh/laws-and-legislations/sub-decree/sd20-50.html#.X037ue_is2x

[11] រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ លេខ ១១២៣ សជណ ស្តីពីការចាត់វិធានការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។ ថ្ងៃសុក្រ ៣ រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០។

[12] សេចក្តីជូនដំណឹងស្តីពី វិធានការបង្ការជំងឺកូវីដ ១៩ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងអំឡុងពេលលើកការឈប់សម្រាកបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។

[13] សេចក្តីសម្រេចស្តីពីការបញ្ចប់សុពលភាពបទបញ្ជាលេខ ០២ ប.ប. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ ដោយរាជរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០។

[14] សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចាប់ផ្តើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធាណៈ និងឯកជនទូទាំងប្រទេស។ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។ https://drive.google.com/file/d/1YyqLk8Wgqy50D4D0-WnO_W2cZNKSAcpH/view

ចូលរៀនឡើងវិញ[15] វិធានការបន្ថែមក្នុងការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩[16] សេចក្តីប្រកាសព័ត៌មានពីការរៀនតាមប្រព័ន្ធអេឡិចត្រូនិក (E-learning) សម្រាប់ជំនួយដល់សិស្សានុសិស្ស[17] និងការរៀបចំ និងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឪជីថល និងការអប់រំពីចម្ងាយ[18] ជាដើម។

## បទពិសោធ និងទស្សនៈរបស់សិស្ស-និស្សិត

សិស្ស-និស្សិត៩៣ភាគរយ ថាបានទទួលព័ត៌មានពីជំងឺកូវីដ ១៩ ដូចជាអំពីរោគសញ្ញា ការបង្ការការពារ និងស្ថិតិនៃចំនួនករណីនៃជំងឺកូវីដ ១៩ជាដើមពីក្រសួងសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន។ សិស្ស-និស្សិត៩៦ ភាគរយថាមានការផ្សព្វផ្សាយពីសរាចរ សេចក្តីប្រកាសផ្សេងៗ និងបទបញ្ជារបស់រាជរដ្ឋាភិបាលជុំវិញ វិធានការពារការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ដូចជាការហាមឃាត់ការធ្វើដំណើរឆ្លងស្រុក និងខេត្តទូទាំងប្រទេស ចត្តាឡីស័ក និងពង្រាងច្បាប់ស្តីពីគ្រប់គ្រងប្រទេសក្នុងស្ថិតក្នុងគ្រាអាសន្នជាដើម។[19] ផងដែរនោះ សិស្ស-និស្សិតថា អាជ្ញាធរ មូលដ្ឋានបានអនុវត្តបទបញ្ជា និងវិធានផ្សេងៗយ៉ាងសកម្មដូចជាទៅលើការរិតបណ្តឹងការជួបជុំ និងប្រមូលផ្តុំ ជាសាធារណៈ លើកទឹកចិត្តឱ្យប្រជាពលរដ្ឋពាក់ម៉ាស និងការរក្សាអនាម័យជាដើម។



*ការទទួលព័ត៌មាននានា*

ជុំវិញ ការទទួលបានព័ត៌មានពីកម្មវិធីគាំទ្រ ឬការឧបត្ថម្ភនានា របស់រាជរដ្ឋាភិបាល ចំពោះសិស្ស-និស្សិតទាំងសម្ភារៈការពារខ្លួន ស្បៀងអាហារ ការលើកលែង ឬបន្ធូបន្ថយការបង់ថ្លៃសិក្សា ឬបញ្ចុះតម្លៃបន្ទប់ជួល នៅអំឡុងពេលនៃជំងឺកូវីដ១៩ជាដើម។ល។ សិស្ស-និស្សិត៧០.៤ភាគរយ ឆ្លើយថាពួកគេមិនទទួលបានព័ត៌មានជុំវិញការ

---

[15] នាសេចក្តីណែនាំស្តីពីការពន្យារពេលនៃការចូលរៀនឡើងវិញសម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទទាំងសាធារណៈ និងឯកជន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូទៅទាំងប្រទេស ដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០។

[16] សេចក្តីណែនាំស្តីពីវិធានការបន្ថែមក្នុងការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ ដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។

[17] សេចក្តីប្រកាសព័ត៌មានចេញដោយក្រសួងអប់រំ យុវជន និងកីឡា ស្តីពី "ការរៀនតាមប្រព័ន្ធអេឡិចត្រូនិ (E-learning) សម្រាប់ជំនួយដល់សិស្សានុសិស្ស" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។ https://drive.google.com/file/d/19KV_MHm2FEgvaena_q_xXKcPqBntbn3A/view

[18] ប្រកាសស្តីព ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

[19] កិច្ចសម្ភាសន៍ធ្វើឡើងជាមួយសិស្សនិស្សិតនៅអំឡុងពេលនៃពង្រាងច្បាប់

ផ្សព្វផ្សាយ។

សិស្ស-និស្សិតថា ពួកគេបានទទួលព័ត៌មានផ្សេងៗពីប្រភពព័ត៌មានដូចជាៈ បណ្តាញព័ត៌មានសង្គម ការផ្សព្វផ្សាយពីអាជ្ញាធរមូលដ្ឋានតាមផ្ទះ ទូរទស្សន៍ កាសែត សេចក្តីប្រកាស ឬសេចក្តីថ្លែងការណ៍នានារបស់រាជរដ្ឋាភិបាល និងក្រសួងជាដើម។

សិស្ស-និស្សិតមួយចំនួន ប្រាប់ថាអាជ្ញាធរមូលដ្ឋានមានភាពសកម្មក្នុងការអនុវត្តវិធាន បង្ការតាមរយៈ ការចុះតាមផ្ទះរបស់ប្រជាពលរដ្ឋណែនាំពីការការពារខ្លួន ផ្សព្វផ្សាយសេចក្តីជូនដំណឹង ឃ្លាំមើលការវិវឌ្ឍនានានៅតាមភូមិ និងអនុវត្តចត្តាឡីស័កទៅលើប្រជាពលរដ្ឋមួយចំនួនដែលវិលត្រឡប់ពីធ្វើការនៅក្រៅប្រទេស។ យ៉ាងហោចណាស់សិស្ស-និស្សិតបីនាក់ ប្រាប់ថានៅមានប្រជាពលរដ្ឋមួយចំនួន ដែលវិលត្រឡប់ពីធ្វើការក្រៅប្រទេសនៅក្នុងសហគមន៍របស់ពួកគេ។

សិស្ស-និស្សិតមួយចំនួន គាំទ្រចំណាត់ការរបស់រាជរដ្ឋាភិបាល ព្រមទាំងក្រសួងពាក់ព័ន្ធមួយចំនួនដោយពួក គេយល់ឃើញ ថាវិធានទាំងនោះដែលវិធាននៃការហាមប្រាមការធ្វើដំណើរពីខេត្ត មួយទៅខេត្តមួយទៀតនា អំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិ ជាការអនុវត្តល្អដើម្បីបង្ការការរីករាលដាលនៃមេរោគកូវីដ ១៩ មកលើប្រជាជនកម្ពុជា។

ដោយឡែក សិស្ស-និស្សិតមួយចំនួនទៀត បង្ហាញនូវក្តីព្រួយបារម្ភ និងភាពភ័យខ្លាចចំពោះការដាក់ចេញនិងអនុវត្តនូវបទបញ្ជានេះ។ ពួកគេថា ការបិទច្រកចេញចូលពីស្រុកមួយ ខេត្តមួយ ទៅស្រុក ខេត្តមួយទៀតធ្វើឡើងយ៉ាងឆាប់រហ័ស ធ្វើឲ្យពួកគេមានក្តីបារម្ភពីការវិវឌ្ឍនៃស្ថានភាពនៅក្នុងប្រទេសកម្ពុជាកាន់តែអាក្រក់ឡើង។

ជាក់ស្តែងសម្រាប់សិស្ស-និស្សិតមួយចំនួន ដែលមកស្នាក់នៅទីក្រុងភ្នំពេញ ពួកគេមានក្តីបារម្ភជាខ្លាំងថាពួកគេមិនអាចត្រឡប់ទៅជួបជុំក្រុមគ្រួសារបាននាពេលនោះ។

បន្ថែមទៅលើការផ្សព្វផ្សាយព័ត៌មាន សិស្ស-និស្សិតមួយចំនួនយល់ឃើញថា ធនធានជាច្រើនដែលរួមទាំងការពិនិត្យធ្វើតេស្តរកមេរោគកូវីដ ១៩ ការថែទាំ និងព្យាបាលជំងឺនេះ ត្រូវបានប្រមូលផ្តុំតែនៅទីក្រុងភ្នំពេញប៉ុណ្ណោះ ហើយជារឿយៗនៅតាមបណ្តាខេត្ត និងតំបន់ដាច់ស្រយាល មិនទាន់មានការអនុវត្តដោយយកចិត្តទុកដាក់នោះទេ។

## ផលប៉ះពាល់ពីការផ្អាកដំណើរការគ្រឹះស្ថានអប់រំ

សិស្ស-និស្សិត២៧ភាគរយ ឆ្លើយថាពួកគេពេញចិត្តចំពោះសេចក្តីជូនដំណឹងស្តីពីការឈប់វិស្សមកាលតូចមុនកាលកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។ ពួកគេយល់ឃើញថា សេចក្តីជូនដំណឹងនេះធ្វើឡើងដើម្បីការពារសុវត្ថិភាព និងសុខមាលភាពរបស់ពួកគេ។ ជុំវិញការអនុវត្តសេចក្តីជូនដំណឹងនេះ សិស្ស-និស្សិតមួយចំនួនក៏បានបន្ថែមថា ពួកគេមានការសប្បាយដោយសារពួកគេអាចមានពេលវេលាសម្រាកច្រើនជាងមុន ដែលជាធម្មតាការឈប់សម្រាកវិស្សមកាលតូចមានរយៈពេលខ្លី។

ក៏ប៉ុន្តែមានការយល់ឃើញផ្ទុយគ្នាទៅលើសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការពន្យារពេលនៃការចូលរៀនឡើងវិញ ត្រូវបានលើកឡើងក្នុងចំណោមសិស្ស-និស្សិត។ ក្នុងនោះ សិស្ស-និស្សិតជិត ៤២ភាគរយ បង្ហាញថាពួកគេមានអារម្មណ៍ស្មុគស្មាញ ១៥.២ភាគរយ ភ័យបន្ទាប់ពីបានទទួលដំណឹងពីការពន្យារពេលនៃការចូលរៀន។




*អារម្មណ៍ពីការផ្អាកដំណើរការសិក្សា*

សិស្ស-និស្សិតមួយចំនួនមានការខ្វល់ខ្វាយពីការអាក់ខានការសិក្សារបស់ពួកគេ ដែលបញ្ហានេះអាចធ្វើឱ្យរាំងស្ទះដល់ការបញ្ចប់ការសិក្សារបស់ពួកគេ។ មួយចំនួនទៀត មានអារម្មណ៍ស្អុគស្អាញ និងបារម្ភជាខ្លាំងទៅលើភាពមិនប្រាកដប្រជានៃការវិវឌ្ឍនៃការរាតត្បាតនៃជំងឺកូវីដ ១៩ ជាពិសេសផលប៉ះពាល់របស់វាមកលើជីវភាពរស់នៅរបស់គ្រួសារពួកគេ។

សិស្ស-និស្សិតមួយចំនួនធំ បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនដែលពួកគេជួបប្រទះក្នុងអំឡុងពេលនៃការបិទផ្អាកសាលារៀន មហាវិទ្យាល័យ និងសកលវិទ្យាល័យ។ ក្នុងនោះបញ្ហាចម្បងសម្រាប់ពួកគេ គឺការធ្លាក់ចុះនូវគុណភាព និងប្រសិទ្ធភាពនៃការសិក្សា។ បើទោះបីជា សិស្ស-និស្សិតមួយចំនួនថា ពួកគេ បានបន្តសិក្សាដោយខ្លួនឯង ក៏ប៉ុន្តែការរៀនបែបនេះ គឺមិនបានគ្រប់ជ្រុងជ្រោយដូចជាការសិក្សានៅក្នុងថ្នាក់រៀនជាមួយគ្រូនោះទេ។ សិស្ស-និស្សិតមួយចំនួនទៀត ផ្តល់ចម្លើយប្រហាក់ប្រហែលគ្នាទៅលើភាពខុសគ្នានៃប្រសិទ្ធភាពនៃការសិក្សានៅក្នុងថ្នាក់ជាមួយគ្រូ ទៅនឹងការសិក្សាដោយខ្លួនឯង។ ពួកគេថា ប្រសិទ្ធភាពនៃការសិក្សារបស់ពួកគេមានការធ្លាក់ចុះជាងមុន។ បញ្ហានេះ ធ្វើឱ្យសិស្ស-និស្សិតមួយចំនួន មានក្តីបារម្ភថាពួកគេអាចនឹងប្រឈមទៅនឹងការប្រឡងធ្លាក់នៅពេលសាលារៀនបើកដំណើរការជាធម្មតាឡើងវិញ។ ពួកគេថា មិនចង់រៀនសារឡើងវិញនោះទេ។

រហូតមកដល់ពេលបច្ចុប្បន្ន គ្រឹះស្ថានអប់រំសាធារណៈបន្តផ្អាកដំណើរការ។ ក្រៅពីការអាក់ខានការសិក្សាកន្លងមក សិស្ស-និស្សិតមួយចំនួនលើកឡើង នូវក្តីបារម្ភរបស់ពួកគេចំពោះការបន្តផ្អាកដំណើរការនៃគ្រឹះស្ថានអប់រំអាចធ្វើឱ្យពួកគេត្រូវពន្យារពេលបញ្ចប់ការសិក្សា ឬខាតពេលវេលានៃការសិក្សា។ សិស្ស-និស្សិតមួយចំនួនបារម្ភថាពួកគេមិនអាចបញ្ចប់ការសិក្សាទៅតាមកាល កំ ណត់ ហើយត្រូវរៀនសារឡើងវិញ។ ក្តីបារម្ភនេះ ត្រូវបានលើកឡើងដោយសិស្ស-និស្សិតដែលកំពុងសិក្សាថ្នាក់ទី១២ និងសិស្ស-និស្សិតកំពុងសិក្សានៅ មហាវិទ្យាល័យ ជាពិសេសសម្រាប់សិស្ស-និស្សិតសិក្សាឆ្នាំទី៤។ សិស្សថ្នាក់ទី១២ មួយចំនួនបន្ថែមថាបើក្នុងករណីពួកគេប្រឡងមិនជាប់ ពួកគេនឹងរកការងារធ្វើដោយសារពួកគេគ្មានលទ្ធភាពរៀនសារឡើងវិញនោះទេ។

## បទពិសោធនៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិក

ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក(E-learning)៖ ប្រព័ន្ធនៃការអប់រំមួយបែបដែលមានមូលដ្ឋានចេញពីការអប់រំផ្លូវការ ហើយដោយប្រើប្រាស់ធនធានអេឡិចត្រូនិកជាជំនួយ ដែលមានកម្មវិធីសិក្សា មេរៀន វិធីសាស្ត្របង្រៀន និងការវាយតម្លៃសមត្ថភាពសិស្ស និងលទ្ធផល នៃការសិក្សាដោយនិយាមច្បាស់លាស់។ ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក អាចរៀបចំនៅក្នុង ឬ នៅក្រៅថ្នាក់ ហើយភាគច្រើន គឺប្រើប្រាស់កុំព្យូទ័រ អ៊ិនធើណែត និងប្រើប្រាស់កម្មវិធីកុំព្យូទ័រ ដែលគ្រប់គ្រងដោយប្រព័ន្ធការសិក្សាអេឡិចត្រូនិក។[20]

មានការយល់ឃើញ និងផ្តល់និយមន័យនៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិច ផ្សេងៗគ្នា ក្នុងចំណោមសិស្ស-និស្សិតដែលចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ សិស្ស-និស្សិតភាគច្រើន ហាក់នៅមានភាពស្រពិចស្រពិលទៅលើការរៀនតាមប្រព័ន្ធនេះ។ សិស្ស-និស្សិតមួយចំនួនតូច ដែលមានភាពជឿជាក់ និងចំណេះដឹងក្នុងការបកស្រាយពីទម្រង់និងនិយមន័យនៃការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះ។ តាមការយល់ឃើញរបស់ពួកគេ ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក គឺសំដៅទៅលើការរៀនពីចម្ងាយរបស់សិស្ស-និស្សិតតាមរយៈប្រព័ន្ធវីឌីអូដែលបានថតទុក រួចបង្ហោះទៅក្នុង (យូធូប ឬហ្វេសប៊ុក) ឬជាការសិក្សាតាមប្រព័ន្ធបច្ចេកវិទ្យានាយុគសម័យថ្មី ដូចជាការរៀនតាមថ្នាក់រៀនតាមអ៊ិនធើណែតរបស់ហ្គូលហ្គល (Google Classroom) ឬ Moodle ឬក៏ ជាការរៀនដោយប្រើតាមកម្មវិធីអេបមួយចំនួនទៀតហើយដោយស្របទៅតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

សម្រាប់សិស្ស-និស្សិតដែលមានចំណេះទៅលើប្រព័ន្ធការសិក្សានេះ ភាគច្រើនថា ពួកគេមានបទពិសោធសិក្សាតាមប្រព័ន្ធនេះពីមុន។ គួសបញ្ជាក់ថា សិស្ស-និស្សិតមួយចំនួនកំពុងសិក្សាទាំងនៅគ្រឹះស្ថានអប់រំសាធារណៈ និងគ្រឹះស្ថានអប់រំឯកជន។

[20] ប្រកាសស្តីព ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

សិស្ស-និស្សិត៤៣.៧ភាគរយ ឆ្លើយថា ពួកគេ មិនធ្លាប់រៀនតាមប្រព័ន្ធអេឡិចត្រូនិកពីមុន នោះទេ។ សិស្ស-និស្សិតក្រោម៥៦.៣ ភាគរយផ្សេងទៀត ដែលមានបទពិសោធរៀនតាមប្រព័ន្ធនេះ ជិត៦០ភាគរយឆ្លើយថា ពួកគេធ្លាប់រៀនចន្លោះពេលពី១ខែ ទៅ២ខែ។ ហើយការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះទៀតសោតទើបត្រូវបានអនុវត្តបន្ទាប់ពីមាន សេចក្តីណែនាំតម្រូវពីក្រសួងអប់រំ យុវជន និងកីឡា។



*រៀនតាមប្រព័ន្ធអេឡិចត្រូនិក*

សិស្ស-និស្សិតមួយចំនួនធំ លើកឡើងពីបទពិសោធរបស់ពួកគេទៅលើ ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះ ទាំងអត្ថប្រយោជន៍ និងបញ្ហាប្រឈមនានា។ សិស្ស-និស្សិតយល់ ឃើញថាការសិក្សាតាមប្រព័ន្ធនេះ ជាជម្រើសដ៏ល្អនៅក្នុងបរិបទ នៃការរាតត្បាតនៃជំងឺកូវីដ ១៩ ដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ និងចូលរួមចំណែក ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ ១៩។ សិស្ស-និស្សិតមួយចំនួនបង្ហាញទស្សនៈថា ទោះបីជាការរៀនតាមប្រព័ន្ធ អេឡិចត្រូនិកបានតិចតួចជាងការរៀននៅសាលាដោយផ្ទាល់ក៏ដោយ ក្តីក៏វាមានភាពចាំបាច់សម្រាប់ពួកគេដោយសារការរៀនតាមប្រព័ន្ធនេះអាចឱ្យពួកគេបន្តការសិក្សាបាន ហើយក៏ជាការរៀនដែលផ្លាស់ប្តូរវិធីសាស្ត្រថ្មី។ ពួកគេបន្ថែមថា ការរៀនតាមប្រព័ន្ធនេះ បានបង្កើនចំណេះដឹងខាងផ្នែកមូលដ្ឋានគ្រឹះមួយចំនួននៃបច្ចេកវិទ្យា និងការទាញយកព័ត៌មានពីប្រភពច្រើនជាងមុន។ សិស្ស-និស្សិតមួយចំនួនទៀត ថាការរៀនតាមប្រព័ន្ធអេឡិចត្រូនិកជាចំណុចចាប់ផ្តើមសម្រាប់ពួកគេក្នុងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ។ស្របពេលដែរសិស្ស-និស្សិតមួយចំនួនថាមានការងាយស្រួលសុំច្បាប់និងប្រព្រឹត្តខ្លួន។អត្ថប្រយោជន៍មួយចំនួន ដែលត្រូវបានលើកឡើងដោយសិស្ស-និស្សិតទៅលើការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះផងដែរមានដូចជាកាត់បន្ថយការចំណាយ ទៅលើការសិក្សាក្រៅម៉ោង (រៀនគួរ) ថ្លៃធ្វើដំណើរ ចំណេញពេលវេលា ព្រមទាំងអាចប្រើប្រាស់ពេលវេលាច្រើនជាងមុនក្នុងការជួយការងារផ្ទះ ឬ មុខរបរគ្រួសារ។

សិស្ស-និស្សិតបានលើកឡើងថា ការចំណាយទៅលើការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ជាបញ្ហាចម្បងសម្រាប់ពួកគេ។ ពួកគេថា ការសិក្សាតាមប្រព័ន្ធនេះ គឺមិនបានផ្តល់ដល់សិស្ស-និស្សិតដោយឥតគិតថ្លៃនោះទេ។ ជាក់ស្តែង ដើម្បីអាចរៀនតាមប្រព័ន្ធនេះបាន សិស្ស-និស្សិតត្រូវចំណាយប្រាក់កាសផ្ទាល់ខ្លួនទៅលើឧបករណ៍សិក្សាដូចជាទូរស័ព្ទទំនើប ថេបប្លេត អាយភេត ឬកំព្យូទ័រ ចំណាយទៅលើប្រព័ន្ធអ៊ិនធើណែត និងអគ្គីសនីជាដើម។

ការចំណាយខាងលើនេះ មិនបានរាប់បញ្ចូលការចំណាយរបស់សិស្ស-និស្សិតទៅលើថ្លៃសាលានោះទេ។ បន្ទុកនៃការចំណាយបន្ថែមទាំងនេះ គឺធ្លាក់ទៅលើសិស្ស-និស្សិត ឬ អាណាព្យាបាលពួកគេ។

បន្ថែមទៅលើបញ្ហានៃចំណាយរបស់ពួកគេ សិស្ស-និស្សិតទាំងនោះក៏បានលើកឡើងនូវផលលំបាកមួយចំនួនទៀតដែលពួកគេជួបប្រទះ នៅអំឡុងពេលរៀនតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានរៀបរាប់ដូចខាងក្រោម៖

- សិស្ស-និស្សិតមួយចំនួនមិនមានចំណេះដឹងទៅលើ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ហើយក៏មិនធ្លាប់ទទួលបានការបង្ហាត់បង្ហាញ ឬណែនាំជាមុន មុនពេលចាប់ផ្តើមរៀនតាមប្រព័ន្ធនេះ។

- សិស្ស-និស្សិតថា ការរៀនតាមប្រព័ន្ធនេះ តម្រូវឱ្យពួកគេមានចំណេះដឹងមូលដ្ឋានមួយចំនួនផ្នែកបច្ចេកវិជ្ជា ហើយក្រៅពីចំណេះដឹងនេះ ពាក្យបច្ចេកទេស និងការប្រើប្រាស់ភាសាបរទេសក៏ត្រូវបានប្រើប្រាស់នៅក្នុងថ្នាក់រៀនមួយចំនួនផងដែរ ដែលបានធ្វើអោយពួកគេមួយចំនួនមានការពិបាកចាប់យកមេរៀន។
- ពុំសូវងាយស្រួលក្នុងការសាកសួរ ឬ ឆ្លើយឆ្លងជាមួយគ្រូ ដូចជារៀននៅក្នុងថ្នាក់នោះទេ។
- បញ្ហារអាក់រអួលនៃប្រព័ន្ធអ៊ិនធើណែត ឬគ្មានសេវាគ្របដណ្តប់នៅតាម បណ្តាខេត្តមួយចំនួន។
- បញ្ហារអាក់រអួកនៃប្រព័ន្ធអ៊ិនធើណែតនេះ ធ្វើឲ្យសិស្ស-និស្សិតមួយចំនួន មានការលំបាកក្នុងការផ្តោតទៅលើការរៀនរបស់ពួកគេ ឬក៏ធ្វើឱ្យពួកគេមិនបានចូលរៀនជិតដល់។ ពួកគេថា ពេលខ្លះពួកគេមិនអាចបញ្ជូនកិច្ចការសាលាទៅគ្រូ ឬ ក្រុមការងារទាន់ពេលវេលា។ នៅពេលប្រព័ន្ធអ៊ិនធើណែតមានបញ្ហាម្តងៗ ពួកគេត្រូវចំណាយពេលច្រើនក្នុងការដោះស្រាយបញ្ហាទាំងនោះដោយពេលខ្លះពួកគេត្រូវធ្វើជាថ្មីម្តងទៀត។
- ទំនាក់ទំនងរបស់ពួកគេជាមួយមិត្តភ័ក្តិមិនសូវមានភាពស្និតស្នាលដូចមុន សិស្ស-និស្សិតខ្លះថាពួកគេមានអារម្មណ៍ឯកា។
- ដោយសារបញ្ហាកង្វះខាតជីវភាពគ្រួសារ សិស្ស-និស្សិតមួយចំនួនថា ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនេះ មិនសមស្របជាមួយនឹងស្ថានភាពរបស់ពួកគេឡើយ។ ពួកគេបន្ថែមថា មានបញ្ហាប្រឈមជាច្រើនដែលត្រូវគិត ដូចនេះការរៀនតាមប្រព័ន្ធនេះជាការបន្ថែមបន្ទុកទៅដល់គ្រួសារពួកគេ។ សិស្ស-និស្សិតមួយចំនួន ហាក់បង្ហាញអារម្មណ៍បាក់ទឹកចិត្ត ជាពិសេសនៅពេលដែលពួកគេគ្មានលទ្ធភាពចូលរួមរៀនជាមួយមិត្តភ័ក្តិដទៃ។
- សម្រាប់សិស្ស-និស្សិតដែលឳពុកម្តាយមានមុខរបរនៅផ្ទះ ពួកគេថា ពួកគេមានការលំបាកបន្តិចដោយសារពួកគេត្រូវធ្វើតួនាទីពីរក្នុងពេលតែមួយ គឺត្រូវរៀន និងឆ្លៀតជួយអ្នកផ្ទះផង។
- សិស្ស-និស្សិត និងអាណាព្យាបាលមួយចំនួន បង្ហាញពីក្តីបារម្ភរបស់ពួកគេជុំវិញសុខភាពរាងកាយ និងផ្លូវចិត្តរបស់សិស្ស-និស្សិត ដែលអាចបណ្តាលពីការរៀនតាមប្រព័ន្ធអេឡិចត្រូនិក។ ពួកគេលើកឡើងពីបញ្ហាប្រឈមទៅនឹងជាតិវិទ្យុសកម្មផលប៉ះពាល់ដល់ភ្នែក ជាពិសេសនៅពេលដែលពួកគេត្រូវចំណាយពេលយូរនៅមុខកំព្យូទ័រ ស្តាប់ ឬសម្លឹងទូរស័ព្ទ។
- បញ្ហាការបាត់ទំនាក់ទំនងសង្គម ហើយជំនួសដោយការចំណាយពេលវេលាច្រើនជាមួយឧបករណ៍ក៏ជាក្តីបារម្ភចំពោះការវិវដ្ត ផ្លូវចិត្តរបស់កូនៗពួកគេផងដែរ។

តាមរយៈរបាយការណ៍សិក្សាអង្កេតនាពេលកន្លងមក ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកបន្ថែមបន្ទុកទៅលើឳពុកម្តាយ ឬ អាណាព្យាបាល ជាពិសេសសម្រាប់អាណាព្យាបាលដែលមានកូនតូចៗ ឬមានកូនដែលកំពុងរៀនតាមប្រព័ន្ធនេះ ចាប់ពីពីរនាក់ទៅ។

## ការចំណាយរបស់សិស្ស-និស្សិតមុន និងអំឡុងពេលនៃជំងឺកូវីដ ១៩

សិស្ស-និស្សិតបានចំណាយពីចន្លោះ ១២០,០០០ម៉ឺនរៀល(៣០ដុល្លារ) ទៅ ៤,៨០០,០០០រៀល (១២០០ដុល្លារ) ក្នុងមួយឆ្នាំទៅលើថ្លៃសិក្សាមុនពេលមានការផ្ទុះឡើងនៃជំងឺកូវីដ ១៩។ និស្សិតប្រមាណជា១ភាគ៣

ទទួលបានអាហាររូបករណ៍សម្រាប់ការសិក្សារបស់ពួកគេ ដូចនេះពួកគេបង់តែវិភាគទានតិចតួចទៅដល់សាលាជាថ្លៃរដ្ឋបាល។

សិស្ស-និស្សិតជាង៥០ភាគរយ ចំណាយថវិកាទៅលើទូរស័ព្ទទំនើបរីឯសិស្ស-និស្សិត៤៩ភាគរយផ្សេងទៀតចំណាយទៅលើកុំព្យូទ័រសម្រាប់ជំនួយដល់ការរៀនសូត្ររបស់ពួកគេ។ ការចំណាយទៅលើឧបករណ៍ខាងលើគឺមានចន្លោះពី៥៩៦,០០០រៀល(១៤៩ដុល្លារ) ទៅ៨,០០០,០០០រៀល(២០០០ដុល្លារ)។

សម្រាប់ការចំណាយទៅលើប្រព័ន្ធអគ្គិសនី សិស្ស-និស្សិតចំណាយចន្លោះពី៨០០០រៀល(២ដុល្លារ) ទៅ ៦០០,០០០រៀល(១៥០ដុល្លារ) ក្នុងមួយខែ។ រីឯការចំណាយទៅលើសេវាអ៊ិនធើណែតវិញជាមធ្យមក្នុងមួយខែគឺមាន ចន្លោះពី៤,០០០រៀល (១ដុល្លារ) ទៅ៩៦,០០០រៀល (២៤ដុល្លារ)។

ក្រៅពីការចំណាយខាងលើ សិស្ស-និស្សិតភាគច្រើន ចំណាយទៅលើអាហារ បន្ទប់ជួល សម្ភារៈសិក្សា ថ្លៃធ្វើដំណើរ សំលៀកបំពាក់ ការកំសាន្ត និងរៀនគួរបន្ថែមជាដើម។ ការចំណាយទៅលើបន្ទប់ជួល អាហារសម្លៀកបំពាក់ ធ្វើដំណើរគឺមានចន្លោះពី ២១០,០០០រៀល(៥២.៥ដុល្លារ) ទៅ៤០០,០០០រៀល(១០០ដុល្លារ) ទៅចន្លោះពី៤១០,០០០រៀល (១០២.៥ដុល្លារ) ទៅ ៦០០,០០០រៀល(១៥០ដុល្លារ)ក្នុងមួយខែ។

នៅអំឡុងពេលនៃជំងឺកូវីដ ១៩ សិស្ស-និស្សិតចំណាយពីចន្លោះ២០០,០០០រៀល (៥០ដុល្លារ) ទៅ២,៩២០,០០០ (៧៣០ដុល្លារ) បើប្រៀបធៀបទៅនឹងការចំណាយ មុនពេលមានការផ្ទុះឡើងនៃមេរោគកូវីដ ១៩ តួរលេខខាងលើនេះមានចំនួនទាបជាងការចំណាយតិចជាងមុន របស់សិស្ស-និស្សិត អាចបណ្ដាលពីកត្តាមួយចំនួន។

សិស្ស-និស្សិតមួយចំនួន មិនបានចំណាយបន្ថែមទៅលើថ្លៃសាលានៅឡើយនោះទេ។ ដោយសារមួយចំនួនថាពួកគេបានបង់ថ្លៃសាលាពេញមួយឆ្នាំរួចរាល់ នៅពេលមួយចំនួនទៀតថាបានបង់សា លាចំនួនប្រាំមួយខែមុន ហើយក៏មិនទាន់ដល់ថ្ងៃបង់ថ្លៃសាលាថ្មីនៅឡើយ។



សិស្ស-និស្សិត ៧៣ភាគរយ ឆ្លើយថាពួកគេប្រើប្រាស់ឧបករណ៍ដែលមានស្រាប់ដើម្បីជំនួយដល់ការសិក្សា ជាពិសេសតាមប្រព័ន្ធអេឡិចត្រូនិកក្នុងអំឡុងពេលនៃការរីករាលដាលនៃមេរោគកូវីដ ១៩។ នៅពេលដែរសិស្ស-និស្សិតចំនួន១៣ភាគរយទៀត ឆ្លើយថាពួកគេចំណាយថវិកាទិញទូរស័ព្ទទំនើបដើម្បីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។ ស្របពេលដែរសិស្ស-និស្សិត៧ភាគរយទៀត ចំណាយទៅលើកុំព្យូទ័រ។ ការចំណាយទៅលើឧបករណ៍ទាំងនោះគឺមានចន្លោះពី៦២០,០០០ (១៥៥ដុល្លារ) ទៅ១៦០០,០០០ (៤០០ដុល្លារ)។

សិស្ស-និស្សិតឆ្លើយថា ពួកគេចំណាយពីចន្លោះ៩,០០០រៀល (២.២៥ដុល្លារ) ទៅ៦០០,០០០រៀល (១៥០ដុល្លារ) ក្នុងមួយខែ ទៅលើថ្លៃសេវាអគ្គីសនី និងចំណាយពីចន្លោះ៤,០០០រៀល (១ដុល្លារ) ទៅ៩៦,០០០រៀល (២៤ដុល្លារ)ក្នុងមួយខែទៅលើសេវាអ៊ិនធើណែត។

សិស្ស-និស្សិត៥២ភាគរយ ឆ្លើយថាពួកគេចំណាយក្រោម២០០,០០០រៀល (៥០ដុល្លារ) ក្នុងមួយខែ រីឯសិស្ស-និស្សិត២២ភាគរយ បានចំណាយពីចន្លោះ២១០,០០០រៀល (៥២.៥ដុល្លារ) ទៅ៤០០,០០០រៀល (១០០ដុល្លារ) ក្នុងមួយខែទៅលើអាហារ ធ្វើដំណើរ សម្ភារៈសិក្សា និងបន្ទប់ជួល។ ដោយឡែកសិស្ស-និស្សិត១០ភាគរយ ចំណាយចន្លោះពី៤១០,០០០រៀល(១០២.៥ដុល្លារ) ទៅ៦០០,០០០រៀល (១៥០ដុល្លារ) ក្នុងមួយខែការចំណាយខាងលើនេះ។

សិស្ស-និស្សិតមួយចំនួន លើកឡើងនូវបញ្ហានៃការបន្តបង់ថ្លៃសិក្សារបស់ពួកគេជាមួយគ្រឹះស្ថានអប់រំសាធារណៈ(កម្មវិធីបង់ថ្លៃ) បើទោះបីជាការសិក្សាមានការថយចុះជាងមុនក៏ដោយ។ ពួកគេលើកឡើងថា សាលារដ្ឋគួរមានវិធានការលើកលែងថ្លៃសាលាដល់ពួកគេ ជាពិសេសនៅអំឡុងស្ថានភាពវិបត្តិបែបនេះ។

## ផលប៉ះពាល់លើចំណូលរបស់ឪពុកម្ដាយ/អាណាព្យាបាល

សិស្ស-និស្សិតភាគច្រើនថា ឪពុកម្ដាយ/អាណាព្យាបាល ឬបងប្អូនស្រីប្រុសជាអ្នករកចំណូលចម្បងសម្រាប់គាំទ្រការសិក្សារបស់ពួកគេ។




*អាជីពរបស់ឪពុកម្ដាយ /អាណាព្យាបាល*

សិស្ស-និស្សិត៣៣ភាគរយ ថាឪពុកម្ដាយ ឬអាណាព្យាបាលរបស់ពួកគេមានមុខរបរជាអាជីករ នៅពេលដែរសិស្ស-និស្សិត១៩ភាគរយទៀត មានឪពុកម្ដាយ ឬអាណាព្យាបាលជាកសិករ។ ឪពុកម្ដាយរបស់សិស្ស-និស្សិត១២ភាគរយមានការងារជា មន្ត្រីរាជការ និង១២ភាគរយទៀតជាបុគ្គលិកក្រុមហ៊ុនឯកជន។ សិស្ស-និស្សិតមួយចំនួនតូចទៀតមានឪពុកម្ដាយ ឬអាណាព្យាបាលជាពលករចំណាកស្រុកនៅប្រទេសកូរ៉េខាងត្បូង ថៃ ឬធ្វើការក្នុងចំការនៅខេត្តផ្សេង ឬក៏ជាអ្នកនេសាទជាដើម។

សិស្ស-និស្សិត៣៩ភាគរយ ដឹងអំពីអ្នករកចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ ហើយក្នុងនោះសិស្ស-និស្សិត៣៧ភាគរយ ប្រាប់ថាឪពុកម្ដាយជាអ្នករកចំណូល និងមានចំណូលពីចន្លោះ៨១០,០០០រៀល (២០២.៥ដុល្លារ) ទៅ១,៦០០,០០០រៀល(៤០០ដុល្លារ) ជាមធ្យមក្នុងមួយខែ។ សិស្ស-និស្សិត ៣៣ភាគរយ មានអាណាព្យាបាលដែលរកចំណូលបានលើសពី២,៤១០,០០០រៀល (៦០២.៥ដុល្លារ) ឡើងទៅ។ សិស្ស-និស្សិត ១៨ភាគរយ ថាឪពុកម្ដាយរបស់ពួកគេរកចំណូលបានជាមធ្យមពីចន្លោះ១៦១០,០០០រៀល (៤០២.៥ដុល្លារ) ទៅ ២៤០,០០០រៀល (៦០០ដុល្លារ) ជាមធ្យមក្នុងមួយខែ។ ចំណែកឯ សិស្ស-និស្សិតចំនួន១១ភាគរយ មានអាណាព្យាបាល ដែលមានចំណូលជាមធ្យមពីចន្លោះ៤១០,០០០រៀល (១០២.៥ដុល្លារ) ទៅ៨០០,០០០រៀល (២០០ដុល្លារ) ក្នុងមួយខែ។

សិស្ស-និស្សិត៣២ភាគរយ ប្រាប់ថាពួកគេធ្វើការងារក្រៅម៉ោងដើម្បីផ្គត់ផ្គង់ខ្លួនឯង និងជួយបងប្អូនដែលកំពុងសិក្សាផ្សេងទៀត ហើយការងារដែលពួកគេធ្វើមានដូចជា ជាបុគ្គលិកតាមភោជនីយដ្ឋាន ឬហាងកាហ្វេ កម្មករសំណង់ លើកឥវ៉ាន់នៅតាមផ្សារ និងទទួលប្រមូលព័ត៌មានក្នុងគម្រោងខ្លីៗនៅតាមក្រុមហ៊ុនឯកជន ឬអង្គការជាដើម។ល។

ក្នុងនោះសិស្ស-និស្សិត៣៤ភាគរយប្រាប់ថា កន្លែងការងារក្រៅម៉ោងរបស់ពួកគេបានផ្អាកដំណើរការ។ សិស្ស-និស្សិត ៦៩ភាគរយ មិនទទួលបានអ្វីទាំងអស់នៅពេលដែលកន្លែងការងារពួកគេពីការផ្អាកដំណើរការ។ មានតែសិស្ស-និស្សិត ១៥ភាគរយប៉ុណ្ណោះ ដែលទទួលបានប្រាក់ខែចុងក្រោយ។

សិស្ស-និស្សិតមួយចំនួន លើកឡើងពីបញ្ហាធ្លាក់ចុះចំណូលគ្រួសារដោយសារការផ្អាកការងារ ឬ មុខរបររបស់ឪពុកម្ដាយ/អាណាព្យាបាល។ សម្រាប់សិស្ស-និស្សិតមួយចំនួន ដែលមានឪពុកម្ដាយ ធ្វើជាពលករនៅប្រទេសក្រៅដូចជាប្រទេសកូរ៉េខាងត្បូង និងប្រទេសថៃជាដើមថា គ្រួសាររបស់ពួកគេទទួលរងនូវផលប៉ះពាល់ដោយសារការផ្អាកការងាររបស់ឪពុកម្ដាយដែលជាប្រភពចំណូលដ៏ចាំបាច់សម្រាប់ផ្គត់ផ្គង់គ្រួសារ។

ក្នុងចំណោមសិស្ស-និស្សិតទាំងនេះ យ៉ាងហោចណាស់សិស្សស្រីម្នាក់ដែលរស់នៅក្នុងខេត្តកំពង់ចាមថា នាងពិចារណាឈប់រៀនដោយសារឪពុកម្ដាយរបស់នាងមិនអាចរកចំណូលបានដូចមុន។ សិស្ស-និស្សិត មួយចំនួនទៀត បានលើកឡើងនូវក្ដីបារម្ភចំពោះ ការបោះបង់ចោលការសិក្សារបស់មិត្តភ័ក្ត្ររួមថ្នាក់មួយចំនួនដោយសារពួកគេគ្មានលទ្ធភាពក្នុងការបន្តការសិក្សា ជាពិសេសសម្រាប់សិស្ស-និស្សិតស្រី ដោយសារបញ្ហាជីវភាព និងការទទួលបន្ទុកជួយគ្រួសារពួកគេ។

សិស្សប្រុសម្នាក់ដែលរស់នៅក្នុងខេត្តសៀមរាប បន្ថែមថាគាត់មានការព្រួយបារម្ភថា ខ្លួននឹងមិនអាចបន្តការសិក្សាឱ្យបានចប់ចុង ចប់ដើមដូចក្ដីបំណងព្រោះមិនចង់ទម្លាក់បន្ទុកបន្ថែមទៅដល់ម្ដាយ ដែលកំពុងធ្វើការនៅ

ប្រទេសថៃ ដើម្បីរកប្រាក់សងបំណុលធនាគារឯកជន ជាពិសេសនៅក្នុងបរិបទនេះ។ ស្រដៀងគ្នានេះដែរនៅអំឡុងពេលនៃការផ្អាកសាលារៀនសិស្ស-និស្សិតមួយចំនួន ដែលមានជីវភាពលំបាក ធ្វើការលក់កម្លាំងពលកម្មដូចជាកម្មករសំណង់ ឬអ្នករត់តុនៅតាមភោជនីយដ្ឋានតូចធំមួយចំនួននៅទីរួមខេត្ត ឬនៅទីប្រជុំជនជិតភូមិរបស់ពួកគេ ដើម្បីរកចំណូលផ្គត់ផ្គង់គ្រួសារ។

*"ការងាររបស់ម៉ែពុកនៅប្រទេសកូរ៉េផ្អាកមួយរយៈហើយ ហើយសូម្បីតែលុយបង់ផ្ទះជួលនៅទីនោះក៏ពួកគាត់ស្ទើរតែគ្មានផង យាយខ្ញុំប្រាប់ថា ម៉ែពុកចង់ឱ្យខ្ញុំប្រឹងរៀនធ្វើម៉េចប្រឡងបាក់ឌុប (ថ្នាក់ទី១២) ឱ្យចប់ ប៉ុន្តែខ្ញុំមិនទាន់ដឹងទេថាអាចរៀនដល់ពេលណា ដោយសារនៅទីនេះគ្រួសារខ្ញុំក៏អត់មានចំណូលដែរ យាយគាត់ចាស់ហើយរកចំណូលមិនបាន។ ខ្ញុំគិតថាចង់ឡាយលក់ឡេ ឬទៅស៊ីឈ្នួលគេទាន់ពេលសាលារៀនកំពុងបិទ" សម្ដីសិស្សស្រីថ្នាក់ទី១២ម្នាក់នៅក្នុងខេត្តកំពង់ចាម។*

*"មិត្តរួមថ្នាក់ខ្ញុំមួយចំនួន ទៅធ្វើជាកម្មករសំណង់នៅសៀមរាប (ទីរួមខេត្ត)។ ខ្ញុំធ្លាប់បបួលពួកគេឱ្យរៀនខ្លួនឯងជាមួយគ្នា ពួកគេថាជាប់រវល់ធ្វើការ។ ខ្ញុំបានសួរពួកគេថា នឹងចូលរៀនវិញទេនៅពេលសាលាបើក ពួកគេឆ្លើយថាអត់ទាន់ដឹងទេ។ ខ្ញុំបារម្ភថាពួកគេនឹងបោះបង់ការសិក្សា បើមើលតាមស្ថានភាពគ្រួសាររបស់ពួកគេនាពេលនេះ។" សិស្សប្រុសម្នាក់ដែលរស់នៅក្នុងស្រុកមួយក្នុងខេត្តសៀមរាប។*

**ផលប៉ះពាល់ និងបញ្ហាប្រឈមនៃកង្វះអាហារ**




*ផលប៉ះពាល់ និងបញ្ហាប្រឈមនឹងកង្វះអាហារ*

សិស្ស-និស្សិត៦.២ភាគរយ ឆ្លើយថាពួកគេមិនមានអាហារទទួលទានគ្រប់គ្រាន់នាពេលបច្ចុប្បន្ន ឬក៏អំឡុងពេលនៃកិច្ចសម្ភាសន៍។ សិស្ស-និស្សិត៩៣.៨ភាគរយទៀត ឆ្លើយថាពួកគេមានអាហារសម្រាប់ទទួលទានគ្រប់គ្រាន់សម្រាប់ពេលបច្ចុប្បន្ន។

ប្រភពអាហារដែលគ្រួសារពួកគេមាន ឬប្រើប្រាស់បានមកពី៖ ផ្សារក្នុងភូមិ ឬផ្សារក្នុងសហគមន៍ដែលជិតផ្ទះរបស់ពួកគេ ចំការដំណាំ ឬការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដូចជាមាន់ ទា ត្រី និងជ្រូកជាដើម។ សិស្ស-និស្សិតមួយចំនួនថា ឪពុកម្តាយរបស់ពួកគេបានទិញអាហារស្តុកទុកជាមុនដើម្បីបង្ការវិបត្តិកង្វះស្បៀងអាហារស្របពេលសិស្ស-និស្សិតមួយចំនួនថា គ្រួសារពួកគេបានធ្វើស្រែដូចនេះមានស្រូវច្រើនគួរសមសម្រាប់ផ្គត់ផ្គង់ការហូបចុក និងដោះដូរជាមួយទំនិញដទៃទៀត។

សិស្ស-និស្សិតមួយចំនួនតូច គ្រួសារពួកគេមានអាហារទទួលទានដោយសារការឧបត្ថម្ភពីអង្គការមួយ ហើយពួកគេក៏បន្ថែមថា គ្រួសារពួកគេពុំមានលទ្ធភាពទិញស្បៀងទុក ឬមានស្បៀងសម្រាប់បម្រុងទុកនោះទេ ដោយសារពួកគេគ្មានដីធ្លីធ្វើស្រែ។ ការចំណាយក្នុងគ្រួសារគឺមានលក្ខណៈផ្សេងៗគ្នា។ តួរយ៉ាង សិស្ស-និស្សិត២៩ភាគរយប្រាប់ថាគ្រួសារពួកគេចំណាយចន្លោះពី៨១០,០០០រៀល ទៅ១៦០,០០០រៀល(២០២ដុល្លារ ទៅ៤០០ដុល្លារ) ស្របពេលដែលចំនួនសិស្ស-និស្សិត២៩ភាគរយផ្សេងទៀតថា គ្រួសារពួកគេចំណាយចន្លោះពី២,៤១០,០០០រៀលឡើង(៦០២ដុល្លារឡើង)។

សិស្ស-និស្សិត៩៣ភាគរយ ថាអាហារមានការឡើងថ្លៃ។ ក្នុងនោះដែរសិស្ស-និស្សិត៤៣ភាគរយ ថាតម្លៃអាហារឡើងថ្លៃគួរសម២៥ភាគរយថា អាហារឡើងថ្លៃបន្តិចបន្តួច រីឯសិស្សនិស្សិត២២ភាគរយថា តម្លៃអាហារមានការឡើងថ្លៃខ្លាំង។

បើប្រៀបធៀបការចំណាយមុន និងអំឡុងពេលនៃវិបត្តិពីការរាតត្បាតនៃជំងឺកូវីដ ១៩ សិស្ស-និស្សិតថា ការចំណាយទៅលើអាហារនៅក្នុងគ្រួសារពួកគេច្រើនជាងមុន។ ការចំណាយទៅលើអាហារមុនពេលការផ្ទុះឡើងនៃមេរោគកូវីដ ១៩ គឺមានចន្លោះពី៤,០០០រៀល(១ដុល្លារ) ទៅ៥០,០០០រៀល(១២.៥ដុល្លារ) ក្នុងមួយថ្ងៃ បើប្រៀបធៀបទៅនឹងការចំណាយនៅអំឡុងពេលវិបត្តិនេះគឺមានចន្លោះពី១០,០០០រៀល(២.៥ដុល្លារ) ទៅ១០០,០០០រៀល(២៥ដុល្លារ)ក្នុងមួយថ្ងៃ។

សិស្ស-និស្សិត៥៣ភាគរយឆ្លើយថា គ្រួសារពួកគេនឹងប្រឈមនឹងកង្វះស្បៀងអាហារនៅពេលប៉ុន្មានខែខាងមុខ ប្រសិនបើជំងឺរាតត្បាតនេះនៅតែបន្ត ហើយគ្រួសាររបស់ពួកគេនៅមិនអាចបន្តដំណើរការប្រកបរបរ ឬការងារ។

## ផលប៉ះពាល់ និងបញ្ហាប្រឈមនឹងកង្វះទឹក

សិស្ស-និស្សិត១៨.៣ភាគរយថា ពួកគេមិនមានទឹកទទួលទាន និងប្រើប្រាស់គ្រប់គ្រាន់នោះទេនាពេលបច្ចុប្បន្នតួយ៉ាងគ្រួសារសិស្ស-និស្សិត ក្នុងស្រុកចំនួនពីរនៅខេត្តសៀមរាប និងស្រុកមួយចំនួនទៀតក្នុងខេត្តបាត់ដំបង។

សម្រាប់សិស្ស-និស្សិតមួយចំនួនទៀតថា ពួកគេមានទឹកសម្រាប់ទទួលទាន និងប្រើប្រាស់ក្នុងគ្រួសារគ្រប់គ្រាន់ ដោយសារពួកគេមានលទ្ធភាពចំណាយទៅលើធនធាននេះ។ សិស្ស-និស្សិតថា ទឹកដែលក្រុមគ្រួសារគ្រួសាររបស់ពួកគេប្រើប្រាស់មានប្រភពពីអណ្តូងទឹកឯកជនទឹកសុទ្ធរដ្ឋាករទឹកទឹកស្រះទឹកស្ទឹងទឹកភ្លៀងដែលគ្រួសារពួកគេស្តុកទុក និងទឹកទន្លេជាដើម។




*ភាពប្រឈមនឹងកង្វះទឹក*

សិស្ស-និស្សិត៣ភាគរយឆ្លើយថា ទឹកដែលគេទទួលទាន និងប្រើប្រាស់នៅតំបន់ដែលពួកគេរស់នៅមានការឡើងថ្លៃគួសម ហើយសិស្ស-និស្សិត៣ភាគរយទៀតប្រាប់ថា ទឹកមានការឡើងថ្លៃបន្តិចបន្តួចនៅតំបន់របស់ពួកគេ។ សិស្សម្នាក់ឆ្លើយថា គ្រួសាររបស់ពួកគេមានទឹកស្អាតសម្រាប់ទទួលទាន និងប្រើប្រាស់ពីការឧបត្ថម្ភ របស់អង្គការមួយ។ សិស្សម្នាក់ទៀតប្រាប់ថា បញ្ហារាំងស្ងួតកើតឡើងជារៀងរាល់ឆ្នាំ ដោយឡែកឆ្នាំនេះ អាក្រក់ជាងមុន ជាក់ស្តែងអណ្តូងទឹករួម ដែលពួកគេកំពុងប្រើប្រាស់ជាមួយគ្រួសារផ្សេងទៀតនៅក្នុងភូមិ ចាប់ផ្តើមរីងស្ងួតបន្តិចម្តងៗហើយរីងជិតអស់ហើយ។ សិស្សប្រុសម្នាក់នេះថា គេនឹងដឹកទឹកពីស្រុកជិតៗយកមកប្រើប្រាស់នៅពេល ដែលអណ្តូងអស់ទឹក។ អ្វីដែលជាបញ្ហាចោទសម្រាប់គ្រួសារគេនាអំឡុងពេលនេះគឺ សមាជិកគ្រួសារផ្សេងទៀតដូចជាបងស្រី ដែលធ្លាប់រកចំណូលពីការលាងចាននៅខេត្តបាត់បង់ការងារដោយសារភោជនីយដ្ឋាន ដែលគាត់ ធ្វើការបិទដំណើរការ

ដូចនេះពួកគេមានតែការដើររើសខ្ចង និងបេះបន្លែនៅក្នុងបឹងសម្រាប់ទទួលទាន និងលក់ដូរ។ ពួកគេមិនមានធនធានគ្រប់គ្រាន់សម្រាប់ទិញទឹកនោះទេ។

## ការទទួលបានការថែទាំ និងព្យាបាលមុន និងអំឡុងពេលនៃជំងឺកូវីដ១៩




*ស្ថានភាពសុខភាពរបស់ឪពុកម្ដាយសិស្ស-និស្សិត*

សិស្ស-និស្សិត៤៨.២ភាគរយ មានសមាជិកក្នុងគ្រួសារដែលត្រូវជាឪពុក ម្ដាយ ឬជីដូនដែលមានជំងឺប្រចាំកាយជាយូរឆ្នាំ ហើយតម្រូវឱ្យពួកគេប្រើប្រាស់ថ្នាំប្រចាំកាយជាប្រចាំ។ ពួកគេភាគច្រើនមានជំងឺប្រចាំកាយមានដូចជា៖ ជំងឺលើសឈាម ទឹកនោមផ្អែម រលាកក្រពះ គ្រុនពោះវៀន ខ្សោយបេះដូង ជំងឺរលាកសួត ឬជំងឺសន្លាក់ជាដើម។ល។

សិស្ស-និស្សិត៤៩ភាគរយថា គ្រួសាររបស់ពួកគេទិញថ្នាំពីឱសថស្ថានឯកជនដោយសារភាពងាយស្រួល និងរហ័សទាន់ចិត្ត។ រីឯ សិស្ស-និស្សិត៤០ភាគរយថា គ្រួសាររបស់ពួកគេប្រើប្រាស់សេវាថែទាំ និងព្យាបាលសុខភាពនៅមន្ទីរពេទ្យឯកជន។ ដោយឡែក សិស្ស-និស្សិត១៣ភាគរយផ្សេងទៀតថា សមាជិកគ្រួសាររបស់ពួកគេទៅប្រើប្រាស់សេវាព្យាបាល និងថែទាំសុខភាពនៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យសាធារណៈ។

សិស្ស-និស្សិត១៩ភាគរយថា គ្រួសារពួកគេធ្លាប់ជួបនឹងបញ្ហាការចំណាយទៅលើថ្នាំដែលសមាជិកគ្រួសារពួកគេប្រើប្រាស់ជាប្រចាំជាមួយតម្លៃថ្លៃ។ បើទោះជាមានការឡើងថ្លៃក៏ដោយ ពួកគេមិនអាចមិនទិញថ្នាំទាំងនោះទេ ដោយសារវាជាតម្រូវការចាំបាច់ដែលខានមិនបាន។ ស្រដៀងគ្នានេះដែរ សិស្ស-និស្សិត ៨ភាគរយប្រាប់ថា ពេលខ្លះគ្រួសារពួកគេជួបបញ្ហាមិនមានថ្នាំស្តុក ពេលទៅប្រើប្រាស់សេវាថែទាំ និងព្យាបាលនៅមណ្ឌលសុខភាពសាធារណៈ។ ពួកគេថា ការចំណាយទៅលើការថែទាំ និងព្យាបាលសុខភាពជាបន្ទុករបស់គ្រួសារពួកគេ ហើយការចំណាយគឺពេលខ្លះមានចំនួនច្រើន។

សិស្ស-និស្សិត៦១ភាគរយឆ្លើយថា សមាជិកគ្រួសាររបស់ពួកគេធ្លាប់មានជំងឺនៅអំឡុងពេលនៃការរាតត្បាត

នៃជំងឺកូវីដ ១៩នេះ។ ជំងឺទាំងនោះមានដូចជាក្តៅខ្លួន ផ្តាសសាយ និងរាគរូសជាដើម។ សិស្ស-និស្សិតថា បើទោះបីជាមិនមានសញ្ញាណាមួយបញ្ជាក់ថា គ្រួសាររបស់ពួកគេមានជំងឺកូវីដ ១៩ ក៏ប៉ុន្តែនៅពេលដែលពួកគេមានជំងឺមួយក្នុងចំណោមរោគសញ្ញានៃជំងឺកូវីដ ១៩ គ្រួសារពួកគេមានភាពតក់ស្លុត និងភ័យខ្លាចជាខ្លាំង។

សិស្ស-និស្សិត៤៩ភាគរយថា គ្រួសារពួកគេទិញថ្នាំនៅឱសថស្ថានឯកជន ២៦ភាគរយទៀត ទៅប្រើប្រាស់សេវានៅមន្ទីរពេទ្យឯកជននៅពេលមានជំងឺ ហើយសិស្ស-និស្សិត១៦ភាគរយផ្សេងទៀត ជ្រើសយកការសម្រាកព្យាបាលនៅផ្ទះដោយសារ ពួកគេមានការបារម្ភចំពោះការឆ្លងមេរោគកូវីដ ១៩។

## ៥ ការដោះស្រាយបញ្ហា និងត្រៀមខ្លួនរបស់សិស្សនិស្សិត

*"ខ្ញុំធ្លាប់គិតថា បើជំងឺនេះនៅតែបន្ត ខ្ញុំនឹងគាត់ (កូន) នឹងទៅធ្វើការនៅខេត្តផ្សេងនៅអំឡុងពេលដែលសាលាផ្អាក ហើយនៅពេលសាលាបើកដំណើរការវិញ ខ្ញុំនឹងយកគាត់មករៀនវិញ។" អាណាព្យាបាលម្នាក់នៅខេត្តបាត់ដំបង។*

មានការឆ្លើយតបផ្សេងៗគ្នាដោយសិស្ស-និស្សិត ទៅលើការដោះស្រាយបញ្ហា និងការត្រៀមខ្លួនរបស់ពួកគេបើជំងឺកូវីដ ១៩ នៅបន្តទៀត។ យ៉ាងហោចណាស់សិស្ស-និស្សិតពីរនាក់ ឆ្លើយថាពួកគេមិនទាន់ដឹងថាត្រូវធ្វើអ្វីទេបន្តនៅឡើយនោះទេ។ សិស្ស-និស្សិតមួយចំនួនថា ពួកគេចង់ជួយរកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ ឪពុកម្តាយ និងប្អូនៗ ដោយការចេញទៅរកការងារធ្វើនៅទីរួមខេត្ត ខេត្តផ្សេង ឬ ក្រុងភ្នំពេញជាដើម។

ស្របគ្នានេះដែរ អាណាព្យាបាលមួយចំនួនតូច ដែលចូលរួមក្នុងការសិក្សានេះ គាត់ប្រាប់ថាគាត់អាចនឹងយកកូនទៅធ្វើការនៅទីក្រុង ឬនៅតាមតំបន់ផ្សេងទៀតជាមួយដើម្បីជួយរកចំណូលបន្ថែមដើម្បីជួយគ្រួសារ។

សិស្ស-និស្សិតថា គ្រួសារពួកគេបានពិភាក្សាគ្នាថា ពួកគេនឹងកាត់បន្ថយការចាយវាយនៅក្នុងគ្រួសារ។ នៅពេលដែរ សិស្ស-និស្សិតមួយចំនួនទៀតថា គ្រួសារពួកគេនឹងបន្ថែមការដាំដំណាំ និងចិញ្ចឹមសត្វនៅផ្ទះដើម្បីផ្គត់ផ្គង់គ្រួសារមួយផ្នែកទៀត។ សិស្ស-និស្សិតមួយចំនួនទៀតប្រាប់ថា ឪពុកម្តាយរបស់ពួកគេ នឹងសុំចរចាពន្យាពេលបង់សងបំណុលធនាគារឯកជន។

*"ម៉ាក់ថា បើនៅតែបែបហ្នឹង គឺពួកយើងនឹងលក់ទ្រព្យចាយហើយ។ គាត់ថា មានដីធ្លីបន្តិចបន្តួចសម្រាប់លក់បន្ទាន់នៅក្នុងករណីចាំបាច់។" និស្សិតស្រីម្នាក់នៅខេត្តបន្ទាយមានជ័យ*

## ៦. សេចក្តីសន្និដ្ឋាន តម្រូវការចម្បងៗ និងសំណើរបស់សិស្សនិស្សិត

ចាប់តាំងពីការរាតត្បាតនៃជំងឺកូវីដ ១៩ វិស័យអប់រំទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរ។ ការផ្អាកដំណើរការគ្រឹះស្ថានអប់រំ បានធ្វើឱ្យមានការរអាក់រអួលការសិក្សារបស់សិស្ស-និស្សិតជាច្រើននាក់ ព្រមទាំងជះឥទ្ធិពលមកលើគុណភាព និងប្រសិទ្ធភាពនៃការរៀនសូត្ររបស់ពួកគេផងដែរ។

កម្មវិធីសិក្សាមួយចំនួនត្រូវបានដាក់ចុះឱ្យអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡាក្នុងការដោះស្រាយ

បញ្ហាអាក់ខានការសិក្សា និងសម្រាប់ជាជំនួយដល់ការសិក្សារបស់សិស្ស-និស្សិតទូទាំងប្រទេស ក្នុងនោះមានកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកជាដើម។

កម្មវិធីសិក្សាតាមប្រព័ន្ធនេះ ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់សិស្ស-និស្សិតនៅក្នុងបរិបទបច្ចុប្បន្ន។ ទោះជាយ៉ាងនេះក្តី ការសិក្សាតាមប្រព័ន្ធនេះ បានបង្កើនគម្លាតនៃវិសមភាពទៅលើការទទួលបានការសិក្សាសម្រាប់ សិស្ស-និស្សិតមួយចំនួនទៀត ដែលពុំមានលទ្ធភាព ឬពុំមានចំណេះដឹងជាមួយប្រព័ន្ធសិក្សាបែបនេះ។ ដោយសារការសិក្សាតាមប្រព័ន្ធនេះគឺតម្រូវឱ្យមានការចំណាយ ដូចនេះបន្ទុកនៃការចំណាយនានាធ្លាក់ទៅលើសិស្ស-និស្សិត និងគ្រួសាររបស់ពួកគេដោយផ្ទាល់។

ការធ្លាក់ចុះនូវចំណូល និងបាត់បង់មុខរបររបស់ឪពុកម្តាយ ឬអាណាព្យាបាលសិស្ស-និស្សិត នឹងជម្រុញឱ្យសិស្ស-និស្សិតមួយចំនួនដែលមានជីវភាពលំបាកស្រាប់បោះបង់ការសិក្សារបស់ពួកគេ។

ទោះជាយ៉ាងនេះក្តី វិបត្តិលើកនេះ គឺជាបទពិសោធន៍មួយសម្រាប់ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបន្តជានា និងពង្រឹងគុណភាពអប់រំនៅគ្រឹះស្ថានអប់រំសាធារណៈឲ្យបានកាន់តែល្អប្រសើរ និងដើម្បី បញ្ចៀស ឬគ្រប់គ្រងវិបត្តិនានាស្រដៀងគ្នានេះ ដែលអាចកើតឡើងនាពេលអនាគត។

## តម្រូវការ និងសំណើររបស់សិស្ស-និស្សិត ជូនក្រសួងអប់រំ យុវជន និងកីឡា

- ផ្តល់ការគាំទ្រ និងឧបត្ថម្ភដល់សិស្ស-និស្សិត ឬ គ្រួសារសិស្ស-និស្សិត ដែលកំពុងខ្វះខាតដូចជា ថវិកា ស្បៀងអាហារ និងសម្ភារៈការពារខ្លួនមួយចំនួនដូចជាម៉ាស អាលកុល និងសាប៊ូជាដើម ក្នុងអំឡុងពេលនៃជំងឺកូវីដ ១៩។
- ឧបត្ថម្ភឧបករណ៍ និងសម្ភារៈសិក្សាចាំបាច់មួយចំនួនសម្រាប់ការរៀនតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់សិស្ស-និស្សិត ជាពិសេសសិស្ស-និស្សិតពុំមានលទ្ធភាព។
- ធ្វើការបញ្ចុះតម្លៃ ឬ លើកលែងការបង់ថ្លៃសិក្សាសម្រាប់សិស្ស-និស្សិត ក្នុងអំឡុងពេលដ៏លំបាកនេះ ជាពិសេសនៅក្នុងគ្រឹះស្ថានអប់រំសាធារណៈ(កម្មវិធីបង់ថ្លៃ)។
- គាំទ្រប្រព័ន្ធអ៊ិនធើណែតដោយឥតគិតថ្លៃ និងមានសេវាគ្របដណ្តប់ទូទាំងប្រទេសសម្រាប់សិស្ស-និស្សិត។
- ទទូចឱ្យមានការអនុគ្រោះ និងបន្ធូរបន្ថយការប្រលងដល់សិស្សថ្នាក់ទី១២។
- បន្តបញ្ជូនគ្រូបង្រៀនទៅជនបទ និងជួយបង្រៀនដល់ផ្ទះរបស់សិស្ស-និស្សិត។
- បង្កើតកម្មវិធីគាំទ្របង្កើនចំណេះដឹងដល់សិស្ស-និស្សិតដែលពុំមានបទពិសោធន៍ ឬលទ្ធភាពប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក។
- រៀបចំប្រព័ន្ធអប់រំដែលមានភាពងាយស្រួល និងបត់បែនដែលជួយសម្រួលដល់សិស្ស-និស្សិតពុំមានលទ្ធភាពរៀនតាមប្រព័ន្ធអេឡិចត្រូនិក។
- ពង្រឹងវិធីសាស្រ្តនៃការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិកអោយកាន់តែមានប្រសិទ្ធភាព។

## ជូនរាជរដ្ឋាភិបាល

- បន្តអនុវត្តនៅការផ្តល់ការធ្វើតេស្ត ថែទាំ និងព្យាបាលជំងឺកូវីដ ១៩ ដោយឥតបង់ថ្លៃ សម្រាប់ប្រជាពលរដ្ឋ និងធានាថា វ៉ាក់សាំង និងថ្នាំព្យាបាលជំងឺកូវីដ ១៩ ផ្តល់ដល់ប្រជាពលរដ្ឋដោយឥតបង់ថ្លៃ។
- បន្តពង្រឹងសេវាសុខាភិបាលសាធារណៈ ដោយកាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ ទៅលើសេវាថែទាំ និងព្យាបាលសុខភាព។
- ស្នើសុំឱ្យរាជរដ្ឋាភិបាលដាក់ចេញនូវសរាចរ ឬសេចក្តីប្រកាសទាក់ទងនឹងការគ្រប់គ្រងតម្លៃទំនិញនៅលើទីផ្សារ ព្រមទាំងបញ្ចុះតម្លៃអាហារ បន្លែ និងត្រីសាច់ជាដើម។ល។ នៅទីផ្សារ។
- ពន្យារពេលការតម្លើងថ្លៃពន្ធផ្សេងៗ ជាពិសេសក្នុងវិបត្តិនៃជំងឺកូវីដ ១៩។
- ស្នើសូមអោយសម្រួលតម្លៃផ្ទះជួល ឬ ផ្តល់ធនគាំទ្រទៅលើថ្លៃផ្ទះជួលដល់សិស្ស-និស្សិតដែលមកពីបណ្តាខេត្តនានា។
- ផ្តល់ការគាំទ្រ និងឧបត្ថម្ភ អាហារ និងសម្ភារៈការពារជំងឺកូវីដ ១៩ ដល់សិស្ស-និស្សិត និងប្រជាពលរដ្ឋក្រីក្រទូទៅឲ្យបានទូលំទូលាយ។
- ទទូចឱ្យមានការកាត់បន្ថយ ឬ លើកលែងការបង់ថ្លៃទៅលើតម្លៃប្រព័ន្ធអគ្គីសនី និងទឹកសម្រាប់សិស្ស-និស្សិត។
- ស្នើពន្យារពេលការសង ឬក៏ បញ្ចុះការប្រាក់ពីធនាគារឯកជន និងស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជនក្នុងអំឡុងពេលនៃវិបត្តិនេះ។

## ឯកសារយោង

### ច្បាប់ និងសេចក្តីប្រកាស

1. សេចក្រីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលស្តីពីមានករណីជាសះស្បើយ និងមិនមានករណីវិជ្ជមានវីរុសកូវីដ ១៩ ថ្មី នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ https://www.information.gov.kh/detail/483331
2. ក្រសួងអប់រំយុវជន និងកីឡា ស្តីពី "ការសិក្សាពីចម្ងាយ" និង "ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក" សិស្សានុសិស្សកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ http://www.moeys.gov.kh/index.php/kh/laws-and-legislations/instruction/i20-23.html#.X03rx-_is2x
3. សេចក្រីជូនព័ត៌មានរបស់ក្រសួងសុខាភិបាលស្តីពីមានករណីជាសះស្បើយ និងមិនមានករណីវិជ្ជមានវីរុសកូវីដ ១៩ ថ្មី នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ https://www.information.gov.kh/detail/483331
4. សេចក្តីប្រកាសព័ត៌មានចេញដោយក្រសួងអប់រំ យុវជន និងកីឡា ស្តីពី "ការរៀនតាមប្រព័ន្ធអេឡិចត្រូនិ (E-learning) សម្រាប់ជំនួយដល់សិស្សានុសិស្ស" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។ https://drive.google.com/file/d/19KV_MHm2FEgvaena_q_xXKcPqBntbn3A/view
5. រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ លេខ ០០៣ សជន សេចក្តីណែនាំ ស្តីពីការផ្សព្វផ្សាយអំពីវិធានការបង្ការទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០។
6. ក្រសួងមហាផ្ទៃ លេខ ១០០៧ សជណ ស្តីពីវិធានការគ្រប់គ្រងបងប្អូនប្រជាពលរដ្ឋខ្មែរដែលវិលត្រលប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ។ ថ្ងៃសុក្រ ៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០២០។
7. រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ លេខ ៩១៦ សជណ ស្តីពីការផ្អាកជាបណ្តោះអាសន្ននូវការធ្វើដំណើរចេញពីប្រទេសរបស់ប្រជាពលរដ្ឋកម្ពុជា ទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម និងការធ្វើដំណើរចូលព្រះរាជាណាចក្រកម្ពុជារបស់ប្រជាពលរដ្ឋវៀតណាម។ ថ្ងៃព្រហស្បត្តិ៍ ១១រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២០។
8. អនុក្រឹត្យស្តីពី ការលើកការឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ នៅថ្ងៃទី១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នាំ២០២០ ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០។ https://www.moeys.gov.kh/index.php/kh/laws-and-legislations/sub-decree/sd20-50.html#.X037ue_is2x
9. រាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ លេខ ១១២៣ សជណ ស្តីពីការចាត់វិធានការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។ ថ្ងៃ សុក្រ ៣ រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០២០។

10. សេចក្ដីជូនដំណឹងស្ដីពី វិធានការបង្ការជំងឺកូវីដ ១៩ នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ក្នុងអំឡុងពេលលើកការឈប់សម្រាកបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០២០។
11. សេចក្ដីសម្រេចស្ដីពីការបញ្ចប់សុពលភាពបទបញ្ញាលេខ ០២ ប.ប. ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្ដីពីការដាក់កំហិតលើការធ្វើដំណើរក្នុងប្រទេស ក្នុងគោលដៅបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ ដោយរាជរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០។
12. សេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្ដីពីការចាប់ផ្ដើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិតគ្រប់ប្រភេទទាំងសាធារណៈនិងឯកជនទូទាំងប្រទេស។ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។ https://drive.google.com/file/d/1YyqLk8Wgqy50D4D0-WnO_W2cZNKSAcpH/view
13. សេចក្ដីណែនាំស្ដីពីការពន្យារពេលនៃការចូលរៀនឡើងវិញសម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទទាំងសាធារណៈ និងឯកជន និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូទៅទាំងប្រទេស ដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០។
14. សេចក្ដីណែនាំស្ដីពីវិធានការបន្ថែមក្នុងការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩ ដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០។
15. ប្រកាសស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយដោយក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

## របាយការណ៍

1. វិទ្យុវីអូអេ "កម្ពុជាប្រកាសករណីទី១នៃវីរុសកូរ៉ូណាដែលរកឃើញលើជនជាតិចិនម្នាក់នៅខេត្តព្រះសីហនុ" ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ https://khmer.voanews.com/a/first-case-of-coronavirus-confirmed-in-Cambodia/5261841.html
2. របាយការណ៍ពីកិច្ចសម្ភាសន៍ធ្វើឡើងជាមួយសិស្សនិស្សិតនៅអំឡុងពេលនៃពង្រាង ច្បាប់។
3. របាយការណ៍នេះ មិនត្រូវបានផ្សព្វផ្សាយជាសារធារណៈនោះទេ។របាយការណ៍សង្ខេបពីលទ្ធផលនៃការស្ទង់មតិ "បទពិសោធន៍នៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក (E-learning) របស់សិស្សនិស្សិត" រៀបចំដោយអង្គការសកម្មភាពសង្គមដើម្បីសហគមន៍ និងការអភិវឌ្ឍ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០។

រៀបចំ និងផលិតដោយៈ

អាសយដ្ឋានៈ ផ្ទះលេខ១៦៨AZ ផ្លូវលេខ២៧BT សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ខែសីហា ឆ្នាំ២០២០